# សៀវភៅណែនាំស្តីពី ការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់

## ១. ការរៀបចំគម្រោងមូលនិធិឃុំ សង្កាត់



## ១. ការរៀបចំគម្រោងមូលនិធិឃុំ សង្កាត់

- ការរៀបចំគម្រោងត្រូវធ្វើឡើង បន្ទាប់ពីគម្រោងត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់ និងមុនពេលការចាប់ផ្តើមដំណើរការលទ្ធកម្ម ។
- ការរៀបចំគម្រោង គឺជាការសិក្សា និងប្រមូលព័ត៌មានទាំងអស់ដែលត្រូវការ ដើម្បីរៀបចំឱ្យបាននូវគ្រោងការគម្រោង ។

## ១.១. ការពិនិត្យអំពីតម្រូវការនៃការសិក្សាផលប៉ះពាល់បរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចរបស់គម្រោង

- អ្នកជំនួយបច្ចេកទេសត្រូវធ្វើការពិនិត្យគ្រប់គម្រោងឃុំ សង្កាត់ទាំងអស់ ដើម្បីកំណត់អំពីតម្រូវការនៃការសិក្សាផលប៉ះពាល់
  - បរិស្ថាន
  - ដីធ្លី និងឬ
  - ជនជាតិដើមភាគតិច
- បន្ទាប់ពីពិនិត្យរួច អ្នកជំនួយបច្ចេកទេសត្រូវបំពេញនៅក្នុងទម្រង់ទី១។ បើមិនត្រូវការនៃការសិក្សាផលប៉ះពាល់ទេ ត្រូវបញ្ជាក់មូលហេតុឱ្យបានច្បាស់លាស់។
- នេះជាដំណាក់សំខាន់បំផុតដែលត្រូវធ្វើការត្រួតពិនិត្យដោយប្រុងប្រយ័ត្នបំផុត។



ទម្រង់ទី១

**ការពិនិត្យអំពីតម្រូវការនៃការសិក្សា**

**ផលប៉ះពាល់បរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចរបស់គម្រោង**

| | | |
|---|---|---|
| ខេត្ត ក្រុង : | ស្រុក ខណ្ឌ : | ឃុំ សង្កាត់ : |
| ឈ្មោះគម្រោង : | | |
| តើគម្រោងត្រូវធ្វើការសិក្សាផលប៉ះពាល់បរិស្ថានដែរឬទេ? បាទ ☐ ទេ ☐<br>បើមិនត្រូវការ សូមបញ្ជាក់មូលហេតុ : ..........<br>.......... | | |
| តើគម្រោងត្រូវធ្វើការសិក្សាដីធ្លីដែរឬទេ? បាទ ☐ ទេ ☐<br>បើមិនត្រូវការ សូមបញ្ជាក់មូលហេតុ : ..........<br>.......... | | |
| តើគម្រោងត្រូវការរៀបចំវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិចដែរឬទេ? បាទ ☐ ទេ ☐<br>បើមិនត្រូវការ សូមបញ្ជាក់មូលហេតុ : ..........<br>.......... | | |

ថ្ងៃទី...... ខែ.......... ឆ្នាំ....... ថ្ងៃទី...... ខែ.......... ឆ្នាំ.......

**មេឃុំ ចៅសង្កាត់** **អ្នកជំនួយបច្ចេកទេស**

## ១.១. ការពិនិត្យអំពីគម្រូវការនៃ.... (ត)

- គម្រោងដែលត្រូវធ្វើការវិភាគផលប៉ះពាល់បរិស្ថាន គឺជាគម្រោងដែល :
  - ការអនុវត្តនៃគម្រោងនោះអាចបណ្តាលឱ្យមានការខូចខាត ឬប៉ះពាល់ដល់កន្លែងមួយចំនួន ដែលមានសារៈសំខាន់លើផ្នែកបរិស្ថាន ឬវប្បធម៌
  - ការអនុវត្តនៃគម្រោងអាចបណ្តាលឱ្យមានការខូចខាត ឬប៉ះពាល់ដល់ប្រភពផ្គត់ផ្គង់ទឹក ដែលប្រជាពលរដ្ឋ កំពុងប្រើប្រាស់
  - លទ្ធផលនៃគម្រោងនោះ ជាខ្សែផ្លូវថ្មី
  - លទ្ធផលនៃគម្រោងនោះ ជាផ្លូវចាស់ដែលមានស្រាប់ត្រូវបានពង្រីកទទឹងចាប់ពី ២៥%ឡើងទៅ
  - លទ្ធផលគម្រោងនោះ ជាខ្សែទំនប់ ឬខ្សែប្រឡាយថ្មី ឬអាងស្តុកទឹកថ្មី (ធារាសាស្ត្រថ្មី)
  - លទ្ធផលគម្រោងជាខ្សែព្រែកជីកថ្មីសម្រាប់ការធ្វើដំណើរផ្លូវទឹក និងឬផ្គត់ផ្គង់ទឹកប្រើប្រាស់



## ១.១. ការពិនិត្យអំពីគម្រូវការនៃ.... (ត)

កំណត់សម្គាល់ :

- ឃុំដែលស្ថិតក្នុងបញ្ជីតំបន់ងាយទទួលរងផលប៉ះពាល់បរិស្ថាន គ្រប់គម្រោង ទោះជាមាន ឬមិនមានរៀបរាប់ខាងលើ ត្រូវត្រួតពិនិត្យអំពីសក្តានុពលនៃផលប៉ះពាល់បរិស្ថាន។
- ចំពោះគម្រោងដែលពិនិត្យឃើញថា មានសក្តានុពលនៃផលប៉ះពាល់បរិស្ថាន (ពិសេសគម្រោងដូចរៀបរាប់ខាងលើ) ក្រុមការងារសុវត្ថិភាពបរិស្ថាននឹងចាត់តាំងមន្ត្រីចុះពិនិត្យ ទីតាំងគម្រោង និងផ្តល់យោបល់អំពីរបៀបវិភាគបរិស្ថាន និងរបៀបរៀបចំផែនការ គ្រប់គ្រងបរិស្ថាន។
- PID ត្រូវផ្ញើរបាយការណ៍វិភាគបរិស្ថាន និងផែនការគ្រប់គ្រងបរិស្ថាន ក្រុមការងារ សុវត្ថិភាពបរិស្ថានពិនិត្យជាមុន មុននឹងផ្ញើទៅមន្ទីរបរិស្ថានដើម្បីពិនិត្យបញ្ជាក់ បច្ចេកទេស។
- បើពិនិត្យឃើញថា មានចំណុចខុសឆ្គង ឬខ្វះខាតព័ត៌មានដែលត្រូវការកែតម្រូវ ឬបំពេញបន្ថែម ក្រុមការងារត្រូវជម្រាបដល់ខេត្ត ក្រុងវិញក្នុងរយៈពេល១០ថ្ងៃធ្វើការ។
- មុនពេលយល់ព្រមពីក្រុមការងារ PID មិនត្រូវផ្ញើព័ត៌មានគម្រោងទាំងនោះទៅមន្ទីរជំនាញពាក់ព័ន្ធសម្រាប់ការពិនិត្យបញ្ជាក់បច្ចេកទេសឡើយ។

## ១.១. ការពិនិត្យអំពីគម្រោងការនៃ.... (ត)

- គម្រោងដែលត្រូវធ្វើការសិក្សាដីធ្លី គឺជាគម្រោងដែលនឹងប្រើប្រាស់ :
  – ដីបន្តិចបន្តួចដែលប្រើប្រាស់ដោយឯកជន (ដីសាធារណៈ ឬឯកជន) ហើយគ្រប់គ្រួសារ ដែលប៉ះពាល់បានយល់ព្រមប្រគល់ដោយស្ម័គ្រចិត្ត។ មិនមានគ្រួសារណាមួយបានប្រគល់ ដីច្រើនជាង៥%នៃដីដាំដុះសរុប ឬទ្រព្យសម្បត្តិផ្សេងៗមានតម្លៃច្រើនជាង ៤០០.០០០៛។ គម្រោងប្រភេទនេះ មេឃុំចៅសង្កាត់ត្រូវរៀបចំរបាយការណ៍ បរិច្ចាគដីធ្លីដោយស្ម័គ្រចិត្ត។
  – ដីបន្តិចបន្តួចដែលប្រើប្រាស់ដោយឯកជន (ដីសាធារណៈឬឯកជន) ហើយគ្រួសារដែល ដែលប៉ះពាល់ខ្លះ មិនយល់ព្រមប្រគល់ដោយគ្មានសំណងទូទាត់។ មានគ្រួសារខ្លះនឹងត្រូវប្រគល់ដីច្រើនជាង៥%នៃដីដាំដុះសរុប ឬទ្រព្យសម្បត្តិមានតម្លៃច្រើន ជាង ៤០០.០០០៛។ គម្រោងប្រភេទនេះ តម្រូវឱ្យមានរបាយការណ៍លទ្ធកម្មដីធ្លី។
- ចំពោះគម្រោងដែលបណ្តាលឱ្យមានការរុះរើ ឬបំផ្លាញនូវលំនៅដ្ឋាន ឬអគារធ្វើអាជីវកម្មមួយចំនួននៅលើដីដែលកំពុងប្រើប្រាស់ដោយឯកជន (ដីសាធារណៈ ឬជាដីឯកជន) គម្រោងនោះនឹងមិនត្រូវបានគាំទ្រហិរញ្ញវត្ថុពីមូលនិធិឃុំសង្កាត់ឡើយ។



## ១.១. ការពិនិត្យអំពីគម្រោងការនៃ.... (ត)

- គម្រោងដែលត្រូវការរបាយការណ៍ស្តីពីវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច គឺជាគម្រោងទាំងឡាយ ដែលមានទីតាំងស្ថិតនៅក្នុងភូមិនៃបញ្ជីតំបន់ជនជាតិដើមភាគតិច (ភូមិដែលមានជនជាតិដើមភាគតិច រស់នៅលើសពី៥ភាគរយនៃប្រជាពលរដ្ឋក្នុងភូមិសរុប)។

## ១.២. ការបង្កើតគណៈកម្មការគ្រប់គ្រងគម្រោង

- គម្រោងឃុំ សង្កាត់នីមួយៗ មេឃុំ ចៅសង្កាត់ត្រូវបង្កើតគណៈកម្មការគ្រប់គ្រងគម្រោងមួយ ដោយសេចក្តីសម្រេចរបស់ឃុំ សង្កាត់ ។
- នៅក្នុងដំណើរការរៀបចំគម្រោង តួនាទីរបស់គណៈកម្មការគ្រប់គ្រងគម្រោង គឺជួយ និងផ្តល់យោបល់ដល់មេឃុំ ចៅសង្កាត់ និងចូលរួមក្នុងការរៀបចំគម្រោង ។
- សមាសភាពរបស់គណៈកម្មការ គ្រប់គ្រងគម្រោងរួមមាន :
  - មេឃុំ ចៅសង្កាត់
  - សមាជិកគណៈកម្មការលទ្ធកម្មឃុំ សង្កាត់
  - តំណាងអ្នកទទួលផលម្នាក់ ពីភូមិនីមួយៗដែលលទ្ធផលគម្រោងបានស្ថាបនានៅក្នុងភូមិទាំងនោះ ។ បើមានក្រុមប្រើប្រាស់ដែលនឹងទទួលខុសត្រូវសម្រាប់ការប្រើប្រាស់ និងថែទាំ អ្នកតំណាងភូមិគួរមកពីក្រុមប្រើប្រាស់ ។



## ១.៣. ការរៀបចំក្រុមអ្នកប្រើប្រាស់

- គ្រប់គម្រោងឃុំ សង្កាត់ទាំងអស់ត្រូវមានក្រុមអ្នកប្រើប្រាស់មួយ ដែលនឹងទទួលខុសត្រូវក្នុងការប្រើប្រាស់ និងថែទាំលទ្ធផលគម្រោង ។
- គម្រោងមួយចំនួន ក្រុមអ្នកប្រើប្រាស់នេះបានបង្កើតរួចហើយដោយមន្ទីរជំនាញ ។
- ចំពោះគម្រោងណាដែលមិនទាន់បានបង្កើតក្រុមអ្នកប្រើប្រាស់ ឃុំ សង្កាត់ត្រូវតែរៀបចំបង្កើតឡើង នៅដំណាក់កាលចាប់ផ្តើមរៀបចំគម្រោង ។

# ១.៤. ការរៀបចំផែនការសិក្សាគម្រោង

- បន្ទាប់ពីកម្មវិធីវិនិយោគឃុំ សង្កាត់ត្រូវបានអនុម័ត មេឃុំ ចៅសង្កាត់ត្រូវពិភាក្សាជាមួយនឹងអ្នកជំនួយបច្ចេកទេសអំពីគម្រោងដែលមានក្នុងកម្មវិធីវិនិយោគ ដើម្បីរៀបចំផែនការសិក្សាគម្រោង ( ទម្រង់ទី២) ។
- ផែនការសិក្សាគម្រោងត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ ។
- ផែនការការងារនេះត្រូវរៀបចំសម្រាប់ការសិក្សាគម្រោងទាំងអស់ ដែលមានក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់ ហើយដែលត្រូវបានគ្រោងក្នុងការប្រើប្រាស់ថវិកាពី :
  - មូលនិធិឃុំ សង្កាត់ និង
  - ប្រភពផ្សេងទៀតដែលបានបញ្ចូលនៅក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់ ។
- បើមានភាពមិនច្បាស់លាស់អំពីគម្រោងណាមួយដែលត្រូវដាក់ចូលក្នុងផែនការសិក្សាគម្រោង អ្នកជំនួយបច្ចេកទេសត្រូវពិភាក្សា និងព្រមព្រៀងជាមួយមេឃុំ ចៅសង្កាត់ ។



# ១.៤. ការរៀបចំផែនការសិក្សាគម្រោង (ត)

- ជាការសំខាន់ណាស់ដែលអ្នកជំនួយបច្ចេកទេសត្រូវយល់ឱ្យបានច្បាស់ថា :
  - អ្នកជំនួយបច្ចេកទេសត្រូវអនុវត្តការសិក្សាគម្រោង ទៅតាមផែនការការងារនេះ ដោយផ្អែកលើកម្មវិធីវិនិយោគឃុំ សង្កាត់ ។ អ្នកជំនួយបច្ចេកទេសត្រូវចាប់ផ្តើមសិក្សាគម្រោង ដោយមិនចាំបាច់រង់ចាំការអនុម័តគម្រោងថវិកាឃុំ សង្កាត់ឡើយ ។
  - អ្នកជំនួយបច្ចេកទេសត្រូវមានផែនការសិក្សាគម្រោងរយៈពេលមួយឆ្នាំសម្រាប់ឃុំ សង្កាត់នីមួយៗ ។ ផែនការ និងការអនុវត្តតាមផែនការនេះមានសារៈសំខាន់សម្រាប់វាយតម្លៃការបំពេញការងាររបស់ខ្លួន ។

## ១.៤. ការរៀបចំផែនការសិក្សាគម្រោង (ត)

បញ្ជាក់ :

- អ្នកជំនួយបច្ចេកទេសអាចធ្វើសកម្មភាពសិក្សាគម្រោងបានគ្រប់ពេលវេលា អាស្រ័យលើល័ក្ខខ័ណ្ឌសមស្រប និងពេលវេលាដែលអាចធ្វើបាន។
- អ្នកជំនួយបច្ចេកទេសត្រូវសិក្សាគម្រោងទាំងមូល មិនមែនសិក្សាត្រឹមតែលទ្ធផលដែលមាន ថវិកាសម្រាប់អនុវត្តនោះទេ។
- បើគម្រោងមួយដែលត្រូវអនុវត្តរយៈពេលលើសពី១ឆ្នាំ គម្រោងនោះមិនតម្រូវឱ្យធ្វើការសិក្សា២ដង ឬច្រើនដងនោះទេ។
- ការប្រើប្រាស់ និងថែទាំលទ្ធផលគម្រោងចាស់ មិនចាំបាច់ធ្វើការរៀបចំគម្រោងទេ។
- គម្រោងសេវាកម្មរបស់ឃុំសង្កាត់ ត្រូវមានការរៀបចំគម្រោងសម្រាប់តែឆ្នាំដំបូងប៉ុណ្ណោះ។ បន្ទាប់ពីនោះមកការបន្តផ្តល់សេវាកម្ម គឺជាគម្រោងចាស់ វាមិនមែនជាគម្រោងថ្មីនោះទេ។



## ១.៥. ការរៀបចំរៀបចំផែនទីគម្រោង

- ផែនទីគម្រោងត្រូវតែជាផែនទីឃុំ សង្កាត់ដែលបង្ហាញអំពីទីតាំងនៃលទ្ធផលនានារបស់គម្រោង ដែលបានទទួលការពិនិត្យបញ្ជាក់បច្ចេកទេស និងបណ្តាភូមិទាំងឡាយដែលអ្នកទទួលផលរស់នៅ។
- ផែនទីគម្រោងត្រូវប្រថាប់ត្រាគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត ក្រុង។
- មានតែលទ្ធផលដែលបង្ហាញនៅលើផែនទីនេះប៉ុណ្ណោះត្រូវបញ្ចូលទៅក្នុងកិច្ចសន្យាដើម្បីអនុវត្ត។
- បើក្រុមប្រឹក្សាឃុំ សង្កាត់ចង់ផ្លាស់ប្តូរទីតាំងលទ្ធផលគម្រោង ឬបង្កើនបន្ថែម ចំនួនលទ្ធផលគម្រោងត្រូវអនុវត្តនីតិវិធីនៃការពិនិត្យបញ្ជាក់បច្ចេកទេសជាថ្មីឡើងវិញ។

## ១.៦.ការសិក្សា និងប្រមូលព័ត៌មានទូទៅ និងព័ត៌មានបច្ចេកទេស

- អ្នកជំនួយបច្ចេកទេសជួយគណៈកម្មការគ្រប់គ្រងគម្រោងក្នុងការចុះសិក្សាបច្ចេកទេសនៅទីតាំងគម្រោង ដោយសហការយ៉ាងជិតស្និទ្ធជាមួយក្រុមអ្នកប្រើប្រាស់ និងអង្គការសហគមន៍មូលដ្ឋាន ក្នុងគោលបំណងប្រមូលព័ត៌មានសំខាន់ៗ និងចាំបាច់ ដើម្បីបំពេញទម្រង់ព័ត៌មានគម្រោង ទម្រង់ព័ត៌មានបច្ចេកទេស និងទម្រង់នានា។
- ព័ត៌មានទូទៅ និងព័ត៌មានបច្ចេកទេស ប្រើប្រាស់ដើម្បីបង្កើតគ្រោងការគម្រោង។
- ព័ត៌មានបច្ចេកទេសនៃគម្រោងនីមួយៗ អាចខុសៗគ្នាទៅតាមប្រភេទគម្រោងនីមួយៗ។ ព័ត៌មានបច្ចេកទេសត្រូវបំពេញក្នុងទម្រង់ ព័ត៌មានបច្ចេកទេស ដែលមាននៅក្នុងសៀវភៅណែនាំបច្ចេកទេសស្ដីពីគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងសៀវភៅណែនាំបច្ចេកទេសស្ដីពីគម្រោងសេវាកម្មរបស់ គ.ជ.វ.វ។



## ១.៧. ការសិក្សាផលប៉ះពាល់បរិស្ថាន

- គ្រប់គម្រោងឃុំ សង្កាត់ទាំងអស់ដែលបណ្ដាលឱ្យមានផលប៉ះពាល់អវិជ្ជមានដល់បរិស្ថាន និងវប្បធម៌ ត្រូវធ្វើការសិក្សាផលប៉ះពាល់បរិស្ថាន។
- នីតិវិធីនៃការសិក្សាផលប៉ះពាល់បរិស្ថានមានបរិយាយនៅចំណុច ២.៨។
- **កំណត់សម្គាល់ :** ទោះបីជាលទ្ធផលមួយចំនួនរបស់គម្រោងត្រូវបានគាំទ្រដោយមូលនិធិឃុំ សង្កាត់ ហើយលទ្ធផលមួយចំនួន ទៀតត្រូវបានគាំទ្រដោយមូលនិធិផ្សេងក៏ដោយ គម្រោងនោះក៏អាចត្រូវធ្វើការសិក្សាផលប៉ះពាល់បរិស្ថានផងដែរ។

# ១.៨. ការសិក្សាដីធ្លី

- គម្រោងដែលនឹងប្រើប្រាស់ដីបន្តិចបន្តួចដែលប្រើប្រាស់ដោយឯកជន ( ទោះបីដីនោះជាដីសាធារណៈ ឬដីឯកជនក៏ដោយ) ។ ក្នុងករណីនេះ កម្មសិទ្ធិករ ភោគី ឬអ្នកប្រើប្រាស់ដីធ្លីនឹងបាត់បង់សិទ្ធិរបស់ខ្លួនក្នុងការប្រើប្រាស់ដីនោះ និងទ្រព្យសម្បត្តិនានាដែលមាននៅលើដីនោះ ដោយសារការអនុវត្តគម្រោង ។
- ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវតែធ្វើកិច្ចព្រមព្រៀងជាមួយនឹងកម្មសិទ្ធិករ ភោគី ឬអ្នកប្រើប្រាស់ដីធ្លីនោះជាមុន មុនពេលអនុវត្តគម្រោង ( គឺការសិក្សាដីធ្លី) ។
- នីតិវិធីនៃការសិក្សាដីធ្លី មានបរិយាយនៅចំណុច ២.៩ ។
- ទោះបីជាលទ្ធផលមួយចំនួនរបស់គម្រោងត្រូវបានគាំទ្រដោយមូលនិធិឃុំ សង្កាត់ ហើយលទ្ធផលមួយចំនួនទៀតត្រូវបានគាំទ្រដោយមូលនិធិផ្សេងក៏ដោយ គម្រោងនោះក៏ត្រូវធ្វើការសិក្សាដីធ្លីផងដែរ ។



# ១.៩. ការរៀបចំរបាយការណ៍ស្តីពីវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច

- គម្រោងឃុំ សង្កាត់ដែលមានទីតាំងស្ថិតនៅភូមិនៃបញ្ជីតំបន់ជនជាតិដើមភាគតិច ( ភូមិដែលមានជនជាតិដើម ភាគតិចរស់នៅលើសពី៥%នៃប្រជាពលរដ្ឋសរុបក្នុងភូមិ) ចាំបាច់ត្រូវរៀបចំរបាយការណ៍ស្តីពីវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច ។
- នីតិវិធីនៃការរៀបចំរបាយការណ៍ស្តីពីវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិចមានបរិយាយនៅចំណុច២.១០ ។

## ១.១០. ការរៀបចំគ្រោងការគម្រោង

- បន្ទាប់ពីបានប្រមូលព័ត៌មានសព្វគ្រប់ហើយ អ្នកជំនួយបច្ចេកទេសជួយរៀបចំគ្រោងការគម្រោង។
- ចំពោះគម្រោងហេដ្ឋារចនាសម្ព័ន្ធ គ្រោងការគម្រោងរួមមានគំនូសប្លង់គម្រោង សេចក្ដីលម្អិតបច្ចេកទេស និងប្លង់ការដ្ឋាន។ ជាទូទៅគំនូសប្លង់គម្រោងត្រូវផ្អែកតាមសៀវភៅណែនាំបច្ចេកទេសស្ដីពីគម្រោងហេដ្ឋារចនាសម្ព័ន្ធរបស់ គ.ជ.វ.វ។
- ចំពោះគម្រោងសេវាកម្ម គ្រោងការគម្រោងរួមមានការគ្រោងសកម្មភាពអនុវត្តគម្រោងនានា សេចក្ដីលម្អិតបច្ចេកទេស និងគំនូសប្លង់គម្រោង (បើត្រូវការ)។ សេចក្ដីលម្អិតបច្ចេកទេស និងគំនូសប្លង់គម្រោងអាចមាននៅក្នុងសៀវភៅណែនាំបច្ចេកទេសស្ដីពីគម្រោងសេវាកម្មរបស់ គ.ជ.វ.វ។



## ១.១០. ការរៀបចំគ្រោងការគម្រោង

- គ្រោងការគម្រោងមួយដែលល្អ នឹងផ្ដល់លទ្ធផលចំពោះគម្រោងមួយដែល ៖
  - សម្រេចបាននូវគោលបំណង
  - មិនថ្លៃពេកក្នុងការអនុវត្ត
  - មិនមានការលំបាក ឬថ្លៃពេក ក្នុងការប្រើប្រាស់ និងថែទាំ
  - មិនត្រូវការទំហំដីច្រើនជាងទំហំដីដែលជាតម្រូវការចាំបាច់
  - មិនបណ្ដាលឱ្យខូចខាតដល់បរិស្ថាន
- អ្នកជំនួយបច្ចេកទេសនឹងរៀបចំគ្រោងការគម្រោង ប៉ុន្តែមេឃុំ ចៅសង្កាត់ទទួលខុសត្រូវក្នុងការអនុម័តគ្រោងការគម្រោងនេះ។

## ១.១១.ការប៉ាន់ស្មានតម្លៃគម្រោង និងព័ត៌មានលម្អិតនៃលទ្ធផលគម្រោង

- អ្នកជំនួយបច្ចេកទេសនឹងធ្វើការប៉ាន់ស្មានតម្លៃគម្រោង ដោយផ្អែកតាមគោលការណ៍ណែនាំដែលបានកំណត់ ។
- ដើម្បីធ្វើការប៉ាន់ស្មានតម្លៃគម្រោង ជាដំបូងត្រូវធ្វើការប៉ាន់ស្មានតម្លៃនៃលទ្ធផលនីមួយៗ របស់គម្រោង ហើយបន្ទាប់មកត្រូវបូកសរុបតម្លៃប៉ាន់ស្មានរបស់លទ្ធផលនីមួយៗ នៃលទ្ធផលទាំងអស់របស់គម្រោងនោះ ។
- តម្លៃប៉ាន់ស្មានសរុបនៃលទ្ធផលទាំងអស់ គឺជាតម្លៃប៉ាន់ស្មាននៃគម្រោង ។
- អ្នកជំនួយបច្ចេកទេស ក៏ត្រូវជួយមេឃុំ ចៅសង្កាត់ក្នុងការបំពេញទម្រង់លទ្ធផល និងតម្លៃប៉ាន់ស្មានគម្រោងផងដែរ ។
- អ្នកជំនួយបច្ចេកទេសនឹងជួយរៀបចំតម្លៃប៉ាន់ស្មានគម្រោង និង បំពេញទម្រង់លទ្ធផលនិងតម្លៃប៉ាន់ស្មានគម្រោង ហើយមេឃុំ ចៅសង្កាត់ពិនិត្យ និងសម្រេចទៅលើតម្លៃប៉ាន់ស្មានគម្រោង ។



## ១.១២. ផែនការប្រើប្រាស់ និងថែទាំ

ចំពោះគម្រោងនីមួយៗត្រូវមានផែនការប្រើប្រាស់ និងថែទាំ ។ ផែនការនេះត្រូវបង្ហាញអំពី :

ក). ការងារប្រើប្រាស់

- តើមានការងារចាំបាច់អ្វីខ្លះ ក្នុងការប្រើប្រាស់?
- តើនរណាដែលជាអ្នកទទួលខុសត្រូវក្នុងការរៀបចំការងារប្រើប្រាស់នោះ?
- តើការចំណាយទៅលើការងារប្រើប្រាស់នេះ បានមកពីណា?

ខ). ការងារថែទាំជាប្រចាំ

- តើមានការងារថែទាំជាប្រចាំអ្វីខ្លះដែលចាំបាច់ត្រូវមាន?
- តើនរណាដែលជាអ្នកទទួលខុសត្រូវក្នុងការរៀបចំការងារថែទាំជាប្រចាំនេះ?
- តើចំណាយទៅលើការងារថែទាំជាប្រចាំនេះ បានមកពីណា?

## ១.១២. ផែនការប្រើប្រាស់ និងថែទាំ (ត)

### គ). ការងារថែទាំជាខួប

- តើមានការងារថែទាំជាខួបអ្វីខ្លះដែលចាំបាច់ត្រូវមាន?
- តើនរណាដែលជាអ្នកទទួលខុសត្រូវក្នុងការរៀបចំការងារថែទាំជាខួបនេះ?
- តើការចំណាយទៅលើការងារថែទាំជាខួបនេះ បានមកពីណា?
- តើតម្លៃជាមធ្យមក្នុងមួយឆ្នាំសម្រាប់ការងារប្រើប្រាស់ និងថែទាំលទ្ធផលគម្រោងចំណាយអស់តម្លៃប៉ុន្មាន? ។
- តើត្រូវចំណាយប៉ុន្មានពីគម្រោងថវិកាឃុំ សង្កាត់ក្នុងមួយឆ្នាំ?



## ១.១៣ ការពិនិត្យ និងអនុម័តគ្រោងការគម្រោង

- នៅពេលទម្រង់ព័ត៌មានគម្រោង និងឯកសារពាក់ព័ន្ធនានាត្រូវបានរៀបចំរួចរាល់ មេឃុំ ចៅសង្កាត់ត្រូវរៀបចំការប្រជុំមួយនៃគណៈកម្មការគ្រប់គ្រងគម្រោង ។
- គោលបំណងនៃការប្រជុំនេះ គឺដើម្បីពិនិត្យគ្រោងការគម្រោង និងដើម្បីធានាឱ្យមានការយល់ដឹងយ៉ាងពេញលេញអំពីគម្រោង និងផលប៉ះពាល់ដែលរំពឹងទុក ។
- បើអាចធ្វើបាន ការប្រជុំនេះត្រូវបានរៀបចំឡើងជាសាធារណៈនៅទីតាំងគម្រោង ។
- អ្នកជំនួយបច្ចេកទេសចុះហត្ថលេខាលើទម្រង់ព័ត៌មានគម្រោង ដើម្បីបង្ហាញថាគ្រប់ព័ត៌មានទាំងអស់ដែលមាននៅក្នុងទម្រង់ព័ត៌មានគម្រោង គឺត្រឹមត្រូវ ។
- មេឃុំ ចៅសង្កាត់ចុះហត្ថលេខាលើទម្រង់ព័ត៌មានគម្រោង ដើម្បីបង្ហាញថាគាត់បានយល់ព្រមទៅលើព័ត៌មានគម្រោងទាំងនេះ

## ១.១៣ ការពិនិត្យ និងអនុម័តគ្រោងការគម្រោង

មុននឹងមេឃុំ ចៅសង្កាត់ចុះហត្ថលេខាលើទម្រង់ព័ត៌មានគម្រោង ត្រូវឆ្លើយសំណួរសំខាន់ៗមួយចំនួន ដូចខាងក្រោម :

- បើគ្រោងការគម្រោងបានផ្លាស់ប្តូរ តើគម្រោងនឹងនៅតែសម្រេចបាននូវទិសដៅដើមដែរឬទេ?
- តើអ្នកទទួលផលនឹងសប្បាយចិត្តចំពោះលទ្ធផលគម្រោងដែរឬទេ?
- តើមានការព្រមព្រៀងទៅលើតម្លៃប៉ាន់ស្មានដែរឬទេ?
- តើមានបញ្ហាប៉ះពាល់ដីធ្លីដែរឬទេ?
- តើនឹងមានផលប៉ះពាល់បរិស្ថានធ្ងន់ធ្ងរណាមួយដែរឬទេ?
- តើនឹងមានផលប៉ះពាល់ចំពោះជនជាតិដើមភាគតិចដែរឬទេ?
- តើផែនការប្រើប្រាស់ និងថែទាំមានភាពជាក់ស្តែងដែរឬទេ?
- តើអ្នកប្រើប្រាស់គម្រោងនឹងសប្បាយចិត្តក្នុងការបង់ថ្លៃប្រើប្រាស់ និងថែទាំដែរឬទេ?



## ១.១៤ ការពិនិត្យព័ត៌គម្រោងដោយ PID

- អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុងនឹងធ្វើការពិនិត្យ :
  - តើមេឃុំ ចៅសង្កាត់បានផ្តល់ព័ត៌មានចាំបាច់គ្រប់គ្រាន់ហើយឬនៅ?
  - តើគម្រោងនេះស្របទៅតាមផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ដែរឬទេ?
  - តើគម្រោងនេះមានលក្ខណៈសមស្របក្នុងការប្រើប្រាស់មូលនិធិឃុំ សង្កាត់ផ្នែកអភិវឌ្ឍន៍ដែរឬទេ?
  - តើគម្រោងនេះមានផ្ទុយទៅនឹងច្បាប់ដែរឬទេ?
  - តើការពិនិត្យអំពីតម្រូវការនៃការសិក្សាផលប៉ះពាល់បរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ត្រូវបានអនុវត្តទៅតាមនីតិវិធីដែលមានចែងនៅក្នុង ភីម ដែរឬទេ?
- អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុងត្រូវចុះហត្ថលេខាលើទម្រង់ព័ត៌មានគម្រោងនេះ ដើម្បីបង្ហាញថា ខ្លួនបានពិនិត្យរាល់ព័ត៌មានបានចប់សព្វគ្រប់ ។

## ១.១៤ ការពិនិត្យព័ត៌គម្រោងដោយ PID (ត)

- អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុងត្រូវផ្ញើទម្រង់ព័ត៌មានគម្រោង និងឯកសារពាក់ព័ន្ធទាំងនោះមួយច្បាប់ទៅមន្ទីរជំនាញពាក់ព័ន្ធ ដើម្បីពិនិត្យបញ្ជាក់បច្ចេកទេស។
- បើត្រូវការការសិក្សាផលប៉ះពាល់បរិស្ថាន ហើយការសិក្សានេះមិនទាន់បានធ្វើនៅឡើយ PID ត្រូវចាត់ចែងសម្រាប់ការសិក្សាផលប៉ះពាល់បរិស្ថាននេះ។
- បើផលប៉ះពាល់បរិស្ថានមានផលប៉ះពាល់ធំ ឬមធ្យម អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុងត្រូវចាត់ចែងឱ្យមានការរៀបចំផែនការគ្រប់គ្រងបរិស្ថាន។
- ចំពោះឃុំ សង្កាត់ដែលស្ថិតនៅក្នុងបញ្ជីតំបន់ងាយទទួលរងនូវផលប៉ះពាល់បរិស្ថាន PID ត្រូវប្រាកដថា របាយការណ៍សិក្សាផលប៉ះពាល់បរិស្ថាន និងផែនការគ្រប់គ្រងបរិស្ថាន ត្រូវបានពិនិត្យដោយក្រុមការងារសុវត្ថិភាពបរិស្ថានជាមុន មុននឹងផ្ញើព័ត៌មានគម្រោងទៅមន្ទីរជំនាញដើម្បីពិនិត្យបញ្ជាក់បច្ចេកទេស។



## ១.១៤ ការពិនិត្យព័ត៌គម្រោងដោយ PID (ត)

- បើត្រូវការរបាយការណ៍សិក្សាដីធ្លី PID ត្រូវចាត់ចែងដើម្បីរៀបចំរបាយការណ៍សិក្សាដីធ្លីទៅតាមគោលការណ៍ណែនាំ។
- ចំពោះគម្រោងដែលមានទីតាំងនៅក្នុងភូមិនៃនៃបញ្ជីតំបន់ជនជាតិដើមភាគតិច PID ត្រូវប្រាកដថា របាយការណ៍ស្ដីពីវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច ត្រូវបានពិនិត្យដោយក្រុមការងារសុវត្ថិភាពជនជាតិដើមភាគតិចជាមុន មុននឹងផ្ញើព័ត៌មានគម្រោងទៅមន្ទីរជំនាញដើម្បីពិនិត្យបញ្ជាក់បច្ចេកទេស។

# ១.១៤ ការពិនិត្យព័ត៌គម្រោងដោយ PID (ត)

អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុងត្រូវកត់ត្រា ក្នុងសៀវភៅចុះលេខលិខិតចេញ ចូល :

- កាលបរិច្ឆេទដែលបានទទួលព័ត៌មានគម្រោងពីឃុំ សង្កាត់
- កាលបរិច្ឆេទដែលបានទទួលរបាយការណ៍វិភាគបរិស្ថាន និងផែនការគ្រប់គ្រងបរិស្ថាន
- កាលបរិច្ឆេទដែលបានទទួលរបាយការណ៍បរិច្ចាគដីធ្លីដោយស្ម័គ្រចិត្ត ឬលទ្ធកម្មដីធ្លី
- កាលបរិច្ឆេទដែលបានទទួលរបាយការណ៍ស្តីពីវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច
- កាលបរិច្ឆេទដែលបានទទួលការពិនិត្យបញ្ជាក់យល់ព្រមពីក្រុមការងារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចនៃលេខាធិការដ្ឋាន គ.ជ.វ.វ
- កាលបរិច្ឆេទដែលបានបញ្ជូនឯកសារទាំងអស់នេះទៅមន្ទីរជំនាញ
- កាលបរិច្ឆេទដែលទទួលបាននូវការពិនិត្យបញ្ជាក់បច្ចេកទេស និង
- កាលបរិច្ឆេទចុះកិច្ចសន្យាអនុវត្តគម្រោង។



ទម្រង់ទី៣

<table>
<tr><td colspan="4">គម្រោងមូលនិធិឃុំ សង្កាត់<br>សេចក្តីជូនដំណឹងអំពីការពិនិត្យបញ្ជាក់បច្ចេកទេស</td></tr>
<tr><td>ខេត្ត ក្រុង :</td><td>ស្រុក ខណ្ឌ :</td><td>ឃុំ សង្កាត់ :</td><td>លេខកូដ :</td></tr>
<tr><td colspan="4">ឈ្មោះគម្រោង :</td></tr>
<tr><td colspan="3">កាលបរិច្ឆេទដាក់ជូនព័ត៌មានគម្រោង និងឯកសារពាក់ព័ន្ធផ្សេងទៀតទៅអង្គភាពរដ្ឋបាលមូលដ្ឋានខេត្តក្រុង</td><td></td></tr>
<tr><td colspan="3">កាលបរិច្ឆេទផ្ញើរបាយការណ៍វិភាគបរិស្ថាន និងឬផែនការគ្រប់គ្រងបរិស្ថានទៅលេខាធិការដ្ឋាន គ.ជ.វ.វ។<br>ថ្ងៃទី...... ខែ........... ឆ្នាំ........<br>តើលេខាធិការដ្ឋាន គ.ជ.វ.វ បានឆ្លើយតបក្នុងអំឡុងពេល១០ថ្ងៃ?<br>☐ ទេ មិនបានឆ្លើយតប ☐ បាទ បានយល់ព្រម ☐ បាទ បានជំទាស់</td><td>មិនចាំបាច់ផ្ញើទៅលេខាធិការដ្ឋាន គ.ជ.វ.វ<br>☐</td></tr>
<tr><td colspan="3">កាលបរិច្ឆេទផ្ញើរបាយការណ៍ស្តីពីវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិចទៅលេខាធិការដ្ឋាន គ.ជ.វ.វ។<br>ថ្ងៃទី...... ខែ........... ឆ្នាំ........<br>តើលេខាធិការដ្ឋាន គ.ជ.វ.វ បានឆ្លើយតបក្នុងអំឡុងពេល១០ថ្ងៃ?<br>☐ ទេ មិនបានឆ្លើយតប ☐ បាទ បានយល់ព្រម ☐ បាទ បានជំទាស់</td><td>មិនចាំបាច់ផ្ញើទៅលេខាធិការដ្ឋាន គ.ជ.វ.វ<br>☐</td></tr>
<tr><td colspan="3">កាលបរិច្ឆេទដាក់ជូនរបាយការណ៍វិភាគបរិស្ថាន និងឬផែនការគ្រប់គ្រងបរិស្ថានទៅមន្ទីរបរិស្ថាន<br>ថ្ងៃទី...... ខែ........... ឆ្នាំ........<br>តើមន្ទីរបរិសាន បានឆ្លើយតបក្នុងអំឡុងពេល១៥ថ្ងៃ?<br>☐ ទេ មិនបានឆ្លើយតប ☐ បាទ បានយល់ព្រម ☐ បាទ បានជំទាស់</td><td>មិនចាំបាច់ធ្វើការវិភាគបរិស្ថាន<br>☐</td></tr>
</table>

| | |
|---|---|
| កាលបរិច្ឆេទអនុម័តរបាយការណ៍ស្តីពីវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច។<br>ថ្ងៃទី...... ខែ........... ឆ្នាំ....... | មិនចាំបាច់រៀបចំរបាយការណ៍ស្តីពីវិធានការការពារជនជាតិដើមភាគតិច ☐ |
| កាលបរិច្ឆេទអនុម័តរបាយការណ៍បរិច្ចាគដីធ្លីដោយស្ម័គ្រចិត្ត<br>ថ្ងៃទី...... ខែ........... ឆ្នាំ....... | មិនចាំបាច់រៀបចំរបាយការណ៍បរិច្ចាគដីធ្លីដោយស្ម័គ្រចិត្ត ☐ |
| កាលបរិច្ឆេទអនុម័តរបាយការណ៍លទ្ធកម្មដីធ្លី<br>ថ្ងៃទី...... ខែ........... ឆ្នាំ....... | មិនចាំបាច់រៀបចំរបាយការណ៍លទ្ធកម្មដីធ្លី ☐ |
| កាលបរិច្ឆេទបញ្ចប់ការទូទាត់សំណងលទ្ធកម្មដីធ្លី<br>ថ្ងៃទី...... ខែ........... ឆ្នាំ....... | |
| មន្ទីរជំនាញទទួលខុសត្រូវក្នុងការពិនិត្យបញ្ជាក់បច្ចេកទេស | |
| កាលបរិច្ឆេទដាក់ជូនព័ត៌មានគម្រោង និងឯកសារពាក់ព័ន្ធដទៃទៀតទៅមន្ទីរជំនាញ<br>តើមន្ទីរជំនាញ បានឆ្លើយតបក្នុងអំឡុងពេល១៥ថ្ងៃ?<br>☐ ទេ មិនបានឆ្លើយតប ☐ បាទ បានយល់ព្រម ☐ បាទ បានជំទាស់ | |
| ការពិនិត្យបញ្ជាក់បច្ចេកទេសសម្រាប់គម្រោងនេះបានបញ្ចប់ ក្រុមប្រឹក្សាឃុំ សង្កាត់អាចចាប់ផ្តើមដំណើរការលទ្ធកម្មបាន។ | |

ថ្ងៃទិ...... ខែ........... ឆ្នាំ......

**អង្គភាពរដ្ឋបាលមូលដ្ឋាន**



# ១.១៥ ការពិនិត្យបញ្ជាក់បច្ចេកទេស

- មន្ទីរជំនាញមិនមានសិទ្ធិអនុម័តទេ គឺគ្រាន់តែពិនិត្យបញ្ជាក់បច្ចេកទេសប៉ុណ្ណោះ។
- មន្ទីរជំនាញនឹងបដិសេធចំពោះគម្រោង ប្រសិនបើ :
  - មានបញ្ហាបច្ចេកទេសលើគ្រោងការគម្រោងដែលនឹងបណ្តាលឱ្យគម្រោងទទួលបរាជ័យក្នុងការសម្រេចនូវទិសដៅគម្រោង ឬ
  - មានបញ្ហាទំនាស់រវាងផែនការឃុំ សង្កាត់ និងផែនការមន្ទីរជំនាញ។
- មន្ទីរជំនាញមានសិទ្ធិជំទាស់ចំពោះគម្រោងក្នុងរយៈពេល១៥ថ្ងៃ បន្ទាប់ពីទទួលបានទម្រង់ព័ត៌មានគម្រោងពីអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុង។
- បើមន្ទីរជំនាញចង់ធ្វើការជំទាស់ មន្ទីរត្រូវជូនដំណឹងទៅអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុង ហើយអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុងត្រូវជូនដំណឹងទៅមេឃុំ ចៅសង្កាត់។
- បើក្នុងរយៈពេល១៥ថ្ងៃ មន្ទីរជំនាញមិនធ្វើការជំទាស់ទេ នោះមានន័យថា គម្រោងបានទទួលការពិនិត្យបញ្ជាក់បច្ចេកទេសដោយស្វ័យប្រវត្តិ។

## ១.១៥ ការពិនិត្យបញ្ជាក់បច្ចេកទេស (ឥ)

- ចំពោះគម្រោងដែលតម្រូវឱ្យមានការសិក្សាផលប៉ះពាល់បរិស្ថាន ឬដីធ្លី ឬជនជាតិដើមភាគតិច គម្រោងនោះត្រូវចាត់ទុកថាមានការជំទាស់ដោយស្វ័យប្រវត្តិ រហូតទាល់តែ :
  - របាយការណ៍វិភាគបរិស្ថាន ត្រូវបានអនុម័តចំពោះគម្រោងដែលត្រូវការឯកសារនេះ ។
  - របាយការណ៍វិភាគបរិស្ថាន និងផែនការគ្រប់គ្រងបរិស្ថាន ត្រូវបានអនុម័ត ចំពោះគម្រោងដែលត្រូវការឯកសារទាំង២នេះ ។
  - របាយការណ៍បរិច្ចាគដីធ្លីដោយស្ម័គ្រចិត្ត ត្រូវបានអនុម័តចំពោះគម្រោងដែលត្រូវការរបាយការណ៍នេះ ។
  - របាយការណ៍លទ្ធកម្មដីធ្លី ត្រូវបានអនុម័ត និងការរៀបចំការទូទាត់សំណងត្រូវបានអនុវត្តចំពោះគម្រោងដែលត្រូវការការសិក្សាលទ្ធកម្មដីធ្លី ។
  - របាយការណ៍ស្តីពីវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច ត្រូវបានអនុម័តចំពោះគម្រោងដែលពាក់ព័ន្ធនឹងជនជាតិដើមភាគតិច ។



# សៀវភៅណែនាំស្តីពី ការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់

## ២. ការរៀបចំដើម្បីអនុវត្តកិច្ចសន្យា

# ២. ការរៀបចំដើម្បីអនុវត្តកិច្ចសន្យា

២.១. របាយការណ៍នៃការដេញថ្លៃ

២.២. ការផ្លាស់ប្តូរចំនួនលទ្ធផលកិច្ចសន្យា

២.៣. ការបំពេញទម្រង់លទ្ធផល និងតម្លៃកិច្ចសន្យា

២.៤. ផែនការការងាររបស់អ្នកទទួលការ ឬអ្នកផ្តល់សេវាកម្ម

២.៥. ការចុះហត្ថលេខាលើកិច្ចសន្យា

២.៦. ល័ក្ខខ័ណ្ឌនៃកិច្ចសន្យា

២.៧. ការបរិយាយលម្អិតអំពីការងារថែទាំ

២.៨. ព័ត៌មានកិច្ចសន្យា

២.៩. ការកែសម្រួលកិច្ចសន្យា

37

# ២.១. របាយការណ៍នៃការដេញថ្លៃ

- ស្មៀនឃុំ សង្កាត់ត្រូវបំពេញទម្រង់របាយការណ៍ដេញថ្លៃ (ទម្រង់៤២) រួមទាំងអនុសាសន៍របស់គណៈកម្មការលទ្ធកម្ម និងមូលហេតុនានានៃការផ្តល់អនុសាសន៍នោះ។
- មេឃុំ ចៅសង្កាត់ត្រូវចុះហត្ថលេខាលើរបាយការណ៍ដេញថ្លៃ ដើម្បីបង្ហាញ ថាគាត់ទទួលស្គាល់នូវអនុសាសន៍របស់គណៈកម្មការលទ្ធកម្ម។
- របាយការណ៍ដេញថ្លៃនេះមួយច្បាប់ ត្រូវផ្ញើជូនអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុង និងមួយច្បាប់ត្រូវបិទនឹងក្តារព័ត៌មានឃុំ សង្កាត់។
- មន្ត្រីគាំទ្របច្ចេកទេសត្រូវធ្វើរបាយការណ៍សង្ខេបស្តីពីការដេញថ្លៃ (ទម្រង់ទី៤៣) ផ្ញើជូនអភិបាលខេត្ត ក្រុង តាមរយៈអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុង។

38

## ២.១. របាយការណ៍នៃការដេញថ្លៃ (ត)

- បើអ្នកដេញថ្លៃណាគិតថាការដេញថ្លៃនេះប្រព្រឹត្តទៅមិនត្រឹមត្រូវ និងមិនយុត្តិធម៌ ពួកគេមានសិទ្ធិធ្វើការតវ៉ាដល់អភិបាលខេត្ត ក្រុង ដោយធ្វើពាក្យបណ្ដឹងជាលាយល័ក្ខណ៍អក្សរនៅក្នុងអំឡុងពេល**២ថ្ងៃធ្វើការ** បន្ទាប់ពីការប្រកាសលទ្ធផលដេញថ្លៃ ។ ពាក្យបណ្ដឹងនេះ ១ច្បាប់ ត្រូវផ្ញើជូនទៅមេឃុំ ចៅសង្កាត់ ។
- អភិបាលខេត្ត ក្រុង ត្រូវធ្វើសេចក្ដីសម្រេចជាចុងក្រោយទៅលើបណ្ដឹងតវ៉ានេះ នៅក្នុងអំឡុងពេល**៥ថ្ងៃធ្វើការ**។
- មេឃុំ ចៅសង្កាត់មិនគួរចុះហត្ថលេខាលើកិច្ចសន្យានៅក្នុងអំឡុងពេល៧ថ្ងៃធ្វើការ បន្ទាប់ពីរបាយការណ៍ដេញថ្លៃត្រូវបានផ្ញើជូនទៅអង្គភាពរដ្ឋបាលមូលដ្ឋាន ។
- ក្នុងអំឡុងពេល**៧ថ្ងៃធ្វើការ**នេះ អភិបាលខេត្ត ក្រុងមានសិទ្ធិផ្អាកការចុះហត្ថលេខាលើកិច្ចសន្យារបស់មេឃុំ ចៅសង្កាត់ ក្នុងករណីមានបញ្ហាអ្វីមួយកើតឡើង ។



## ២.២. ការផ្លាស់ប្ដូរចំនួនលទ្ធផលកិច្ចសន្យា

- ក្រុមប្រឹក្សាឃុំ សង្កាត់អាចសម្រេចចិត្តប្ដូរចំនួនលទ្ធផលកិច្ចសន្យា បន្ទាប់ពីដេញថ្លៃហើយ និងមុនពេលចុះ កិច្ចសន្យា ដោយសារមានករណី២ អាចកើតឡើង :
  - តម្លៃដេញថ្លៃដែលឈ្នះខ្ពស់ជាងតម្លៃប៉ាន់ស្មាន ដូចនេះក្រុមប្រឹក្សាឃុំសង្កាត់កាត់បន្ថយចំនួនលទ្ធផលកិច្ចសន្យា ដើម្បីធ្វើឱ្យតម្លៃសរុបកិច្ចសន្យា មិនលើសពីចំនួនថវិកាដែលមាននៅក្នុងគម្រោងថវិការបស់ខ្លួន ។
  - តម្លៃដេញថ្លៃដែលឈ្នះទាបជាងតម្លៃប៉ាន់ស្មាន ដូចនេះក្រុមប្រឹក្សាឃុំ សង្កាត់បន្ថែមចំនួនលទ្ធផលកិច្ចសន្យាដោយប្រើថវិកាដែលនៅសល់ ។
- តម្លៃឯកតារបស់លទ្ធផលនីមួយៗ គឺត្រូវតែជាតម្លៃដែលបានដាក់នៅក្នុងសំណើដេញថ្លៃដែលឈ្នះ ។
- ក្រុមប្រឹក្សាឃុំសង្កាត់មិនអាចបន្ថែមលទ្ធផលប្រភេទថ្មីណាមួយបានឡើយ ។

## ២.២. ការផ្លាស់ប្តូរចំនួនលទ្ធផលកិច្ចសន្យា (ត)

- រាល់លទ្ធផលបន្ថែមត្រូវតែទទួលបាននូវការពិនិត្យបញ្ជាក់បច្ចេកទេស និងបង្ហាញនៅលើផែនទីគម្រោងដែលប្រថាប់ត្រា គ.អ.ជ.ខ។
- ក្រុមប្រឹក្សាឃុំ សង្កាត់អាចបន្ថែមតែលទ្ធផលណាដែលបានទទួលការពិនិត្យបច្ចេកទេស ប៉ុន្តែមិនបានបញ្ចូលក្នុងការដេញថ្លៃប៉ុណ្ណោះ។
- បើក្រុមប្រឹក្សាឃុំ សង្កាត់មិនអាចបន្ថែមចំនួនលទ្ធផលដោយសារតែល័ក្ខខ័ណ្ឌខាងលើនេះ ថវិកាដែលសល់ពីការដេញថ្លៃ ក្រុមប្រឹក្សាឃុំ សង្កាត់អាចសម្រេច :
  - ប្រើប្រាស់សម្រាប់សកម្មភាពថែទាំដែលមិនត្រូវការការពិនិត្យបញ្ជាក់បច្ចេកទេស
  - ទុកសម្រាប់ប្រើប្រាស់ឆ្នាំបន្ទាប់។



## ២.៣. ការបំពេញទម្រង់លទ្ធផល និងតម្លៃកិច្ចសន្យា

១). ភូមិ

២). លេខកូដលទ្ធផលគម្រោង

៣). ការធ្វើថ្មី ឬជួសជុល ឬកែលម្អ

៤). បរិមាណ និងឯកតា

៥). ស្តង់ដារទំហំ១ និងស្តង់ដារទំហំ២ (សម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធ)

៦). តម្លៃឯកតា និងតម្លៃលទ្ធផលគម្រោងនីមួយៗ

៧). តម្លៃសរុបកិច្ចសន្យាដែលមិនទាន់បញ្ចូលតម្លៃពន្ធ

៨). ការគណនាតម្លៃពន្ធដែលត្រូវបញ្ចូលទៅក្នុងតម្លៃនៃកិច្ចសន្យា

៩). តម្លៃសរុបកិច្ចសន្យាដែលបញ្ចូលតម្លៃពន្ធ

## ២.៣. ការបំពេញទម្រង់លទ្ធផល និងតម្លៃកិច្ចសន្យា

១). **ភូមិ** : លទ្ធផលកិច្ចសន្យាមួយអាចមាននៅតែក្នុងភូមិមួយប៉ុណ្ណោះ ។

២). **លេខកូដលទ្ធផលគម្រោង** : លទ្ធផលគម្រោងនីមួយៗមានលេខកូដសម្គាល់មួយ ។ លេខកូដលទ្ធផលគម្រោងមាននៅក្នុងបញ្ជីលទ្ធផលគម្រោងស្តង់ដារ ( ឧបសម្ព័ន្ធទី២) ។

៣). **ការធ្វើថ្មី ឬជួសជុល ឬកែលម្អ**

- **ការធ្វើថ្មី** : លទ្ធផលដែលមិនមាននៅទីនោះស្រាប់ទេ ។
- **ការជួសជុល** : លទ្ធផលមាននៅទីនោះរួចហើយ តែវាមានស្ថានភាពទ្រុឌទ្រោម គេនឹងជួសជុលវាឱ្យមានលក្ខណៈល្អដូចមុន ។
- **ការកែលម្អ** : លទ្ធផលមានរួចស្រេចហើយ ដូចនេះបន្ទាប់ពីកែលម្អហើយ លទ្ធផលនោះនឹងល្អប្រសើរជាងនៅពេលសាងសង់លើកដំបូង ។ ឧ. ការក្រាលក្រួសក្រហមលើកដំបូងនៅលើផ្លូវដីស ។



## ២.៣. ការបំពេញទម្រង់លទ្ធផល និងតម្លៃកិច្ចសន្យា (ត)

៤). **បរិមាណ និងឯកតា** : គ្រប់លទ្ធផលគម្រោងទាំងអស់ មានឯកតាស្តង់ដារនៃរង្វាស់ ។ យើងអាចរកឯកតាស្តង់ដារក្នុងបញ្ជីលទ្ធផលគម្រោងស្តង់ដារ ។

៥). **ស្តង់ដារទំហំ១ និងស្តង់ដារទំហំ២** (សម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធ)
ស្តង់ដារទំហំ១ និងស្តង់ដារទំហំ២នៃលទ្ធផលគម្រោងនី១៧ ត្រូវស្រង់ចេញពីបញ្ជីលទ្ធផលគម្រោងស្តង់ដារ ។ ចំពោះលទ្ធផលគម្រោងណាពុំមាននៅក្នុងបញ្ជី ខេត្តក្រុងអាចស្នើសុំមកថ្នាក់ជាតិដើម្បីបញ្ចូលលទ្ធផលគម្រោងទាំងនោះទៅក្នុងបញ្ជីលទ្ធផលគម្រោងស្តង់ដារ ។

៦). **តម្លៃឯកតា និងតម្លៃលទ្ធផលគម្រោងនីមួយៗ** : តម្លៃក្នុងមួយឯកតា ត្រូវតែដូចគ្នាទៅនឹងតម្លៃឯកតាដែលមាននៅក្នុងសំណើដេញថ្លៃដែលឈ្នះ ។ តម្លៃលទ្ធផលនីមួយៗ គឺជាតម្លៃនៃផលគុណតម្លៃឯកតាជាមួយចំនួនឯកតា នៅក្នុងកិច្ចសន្យា ។

៧). **តម្លៃសរុបកិច្ចសន្យាដែលមិនទាន់បញ្ចូលតម្លៃពន្ធ** : តម្លៃសរុបកិច្ចសន្យាដែលមិនទាន់បញ្ចូលតម្លៃពន្ធ គឺជាតម្លៃសរុបនូវរាល់លទ្ធផលគម្រោងទាំងអស់ ។

## ២.៣. ការបំពេញនូវលទ្ធផល និងតម្លៃកិច្ចសន្យា (ត)

### ៨). ការគណនាតម្លៃពន្ធដែលត្រូវបញ្ចូលទៅក្នុងតម្លៃនៃកិច្ចសន្យា

- តម្លៃពន្ធពីរប្រភេទ នឹងត្រូវបញ្ចូលទៅក្នុងតម្លៃកិច្ចសន្យា គឺពន្ធរបបស្វ័យប្រកាស និងពន្ធរបបម៉ៅការ។ អ្នកទទួលការ អ្នកផ្តល់សេវាកម្ម ឬអ្នកផ្គត់ផ្គង់នីមួយៗ នឹងជាប់របបពន្ធណាមួយក្នុងចំណោមប្រភេទពន្ធទាំងពីរនេះ។
- ដូចនេះ អ្នកទទួលការ អ្នកផ្តល់សេវា ឬអ្នកផ្គត់ផ្គង់ទំនិញបង្ហាញប័ណ្ណប៉ាតង់ ដែលមានសុពលភាព ដើម្បីបញ្ជាក់ថា ខ្លួនជាប់ពន្ធរបបស្វ័យប្រកាស និងពន្ធរបបម៉ៅការ។
- ការគណនាតម្លៃទាំងពីរនេះ មានដូចខាងក្រោម :
  - ពន្ធរបបស្វ័យប្រកាស = តម្លៃសរុបកិច្ចសន្យាមិនបញ្ចូលពន្ធ គុណនឹង ១០% ចែកនឹង ១១០% ឬស្មើនឹង តម្លៃសរុបកិច្ចសន្យាមិនបញ្ចូលពន្ធ ចែកនឹង ១១។
  - ពន្ធរបបម៉ៅការ = តម្លៃសរុបកិច្ចសន្យាមិនបញ្ចូលពន្ធ គុណនឹង ៣% ឬស្មើនឹង តម្លៃសរុបកិច្ចសន្យាមិនបញ្ចូលពន្ធ គុណនឹង ០.០៣។



## ២.៣. ការបំពេញនូវលទ្ធផល និងតម្លៃកិច្ចសន្យា (ត)

### ៩). តម្លៃសរុបកិច្ចសន្យាដែលបញ្ចូលតម្លៃពន្ធ

- តម្លៃសរុបកិច្ចសន្យាដែលបញ្ចូលតម្លៃពន្ធ គឺជាតម្លៃសរុបកិច្ចសន្យាដែលមិនទាន់បញ្ចូលតម្លៃពន្ធ (ឬតម្លៃនៃការដេញថ្លៃ) បូកនឹងតម្លៃពន្ធ។
- តម្លៃសរុបកិច្ចសន្យាដែលបញ្ចូលតម្លៃពន្ធនេះ ត្រូវតែបានបង្ហាញក្នុងល័ក្ខខ័ណ្ឌនៃកិច្ចសន្យា។

## ២.៤. ផែនការការងាររបស់អ្នកទទួលការ ឬអ្នកផ្តល់សេវា

- បន្ទាប់ពីអ្នកទទួលការ ឬអ្នកផ្តល់សេវាកម្មយល់ព្រមទទួលយកកិច្ចសន្យា ពួកគេត្រូវរៀបចំផែនការការងារ ហើយដាក់ជូនមេឃុំ ចៅសង្កាត់អនុម័ត។
- មេឃុំ ចៅសង្កាត់ត្រូវអនុម័តផែនការការងារនេះ មុនពេលចុះហត្ថលេខាលើកិច្ចសន្យា។
- អ្នកត្រួតពិនិត្យបច្ចេកទេសជួយដល់អ្នកទទួលការ ឬអ្នកផ្តល់សេវាកម្មក្នុងការរៀបចំផែនការការងារ។
- អ្នកត្រួតពិនិត្យបច្ចេកទេសត្រូវជម្រាបដល់អ្នកទទួលការ ឬអ្នកផ្តល់សេវាកម្មអំពីដំណាក់កាលបច្ចេកទេសសំខាន់ៗ ដែលខ្លួនត្រូវត្រួតពិនិត្យ។

47

## ២.៥. ការចុះហត្ថលេខាលើកិច្ចសន្យា

- មេឃុំ ចៅសង្កាត់ត្រូវអញ្ជើញតំណាង **NGO** អង្គការសង្គមស៊ីវិល និង អង្គការសហគមន៍មូលដ្ឋាន ដែលធ្វើការងារនៅក្នុងឃុំ សង្កាត់របស់ខ្លួន ដើម្បីចូលរួមនៅក្នុងការប្រជុំចុះកិច្ចសន្យាជាមួយអ្នកទទួលការ ឬអ្នកផ្តល់សេវាកម្ម ក្នុងនាមជាអ្នកសង្កេតការណ៍។
- តំណាង **NGO** អង្គការសង្គមស៊ីវិល និង អង្គការសហគមន៍មូលដ្ឋាន ត្រូវចុះឈ្មោះ និងចុះហត្ថលេខារបស់ខ្លួននៅក្នុងបញ្ជីវត្តមាននៃការប្រជុំចុះហត្ថលេខាលើកិច្ចសន្យា។

48

# ២.៥. ការចុះហត្ថលេខាលើកិច្ចសន្យា (ត)

ឯកសារកិច្ចសន្យា ចែកចេញជា ៦ ផ្នែក ៖

១). ល័ក្ខខ័ណ្ឌនៃកិច្ចសន្យា

២). គំនូសប្លង់ និងសេចក្តីលម្អិតបច្ចេកទេស

៣). ផែនទីគម្រោងដែលមានប្រថាប់ត្រា គ.អ.ជ.ខ

៤). សំណើដេញថ្លៃដែលឈ្នះក្នុងការដេញថ្លៃ

៥). លទ្ធផល និងតម្លៃកិច្ចសន្យា

៦). ផែនការការងាររបស់អ្នកទទួលការ

- ត្រូវចុះហត្ថលេខាលើល័ក្ខខ័ណ្ឌកិច្ចសន្យាចំនួន៣ច្បាប់ និងឯកសារដទៃទៀតចំនួន ២ច្បាប់ លើកលែងតែ ឯកសារទី៣, ទី៤ និងទី៥ ។
- ល័ក្ខខ័ណ្ឌកិច្ចសន្យាត្រូវប្រថាប់ត្រានៅសាខាពន្ធដារខេត្ត ក្រុងយ៉ាងតិច១ច្បាប់ ហើយតម្កល់ទុកនៅរតនាគារខេត្ត ក្រុង (អ្នកទទួលការទទួលខុសត្រូវ) ។



# ២.៥. ការចុះហត្ថលេខាលើកិច្ចសន្យា (ត)

មេឃុំចៅសង្កាត់ត្រូវផ្ញើឯកសារខាងក្រោមនេះ១ច្បាប់ជូនរតនាគារខេត្ត ក្រុង ៖

- លិខិតដែលបញ្ជាក់អំពីការសម្រេចយកអ្នកផ្តល់សេវាកម្ម
- ល័ក្ខខ័ណ្ឌកិច្ចសន្យាច្បាប់ដើម
- ព័តិមានកិច្ចសន្យា

## ២.៥. ការចុះហត្ថលេខាលើកិច្ចសន្យា (ត)

**បញ្ជាក់ :**

- ជាធម្មតា ប្រធានក្រុមហ៊ុន ឬប្រធានអង្គភាព ឬប្រធានអង្គការ ជាអ្នកចុះហត្ថលេខាលើ គ្រប់ឯកសារទាក់ទងនឹងកិច្ចសន្យាទាំងអស់ ។
- ប៉ុន្តែក្នុងករណីប្រធានអវត្តមាន តំណាងក្រុមហ៊ុន ឬអង្គភាព ឬអង្គការដែលទទួលបាននូវការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរ អាចចុះហត្ថលេខាលើឯកសារកិច្ចសន្យានានាបាន ហើយលិខិតផ្ទេរសិទ្ធិនេះ ត្រូវភ្ជាប់ជាមួយឯកសារកិច្ចសន្យា ។
- នៅក្នុងឯកសារកិច្ចសន្យា ត្រូវសរសេរឈ្មោះប្រធានក្រុមហ៊ុន (យកតាមប័ណ្ណប៉ាតង់) ឬប្រធានអង្គភាព ឬប្រធានអង្គការ ពីព្រោះឃុំ សង្កាត់ត្រូវចេញអាណត្តិបើកប្រាក់ឱ្យទៅប្រធានក្រុមហ៊ុន ឬប្រធានអង្គភាព ឬប្រធានអង្គការ ។

51

## ២.៥. ការចុះហត្ថលេខាលើកិច្ចសន្យា (ត)

**បញ្ជាក់ (ត):**

- នៅពេលចុះហត្ថលេខាលើកិច្ចសន្យា អ្នកទទួលការ ឬអ្នកផ្តល់សេវាកម្មដែលជាអង្គភាពរកប្រាក់ចំណេញ ត្រូវយកមកជាមួយនូវប័ណ្ណប៉ាតង់ដែលមានសុពលភាព (ច្បាប់ថតចម្លង) នៅក្នុងខេត្ត ក្រុងដែលខ្លួនបានឈ្នះក្នុងការដេញថ្លៃ ដើម្បីភ្ជាប់ជាមួយឯកសារកិច្ចសន្យា ។
- ប័ណ្ណប៉ាតង់នេះត្រូវបានប្រើប្រាស់សម្រាប់ជាមូលដ្ឋានគណនាតម្លៃបង់ពន្ធ ដើម្បីបញ្ចូលក្នុងតម្លៃកិច្ចសន្យា ។
- ក្នុងករណីកិច្ចសន្យាអនុវត្តឆ្លងឆ្នាំ តម្លៃបង់ពន្ធនៅតែផ្អែកតាមប័ណ្ណប៉ាតង់នៅក្នុងពេលចុះហត្ថលេខាលើកិច្ចសន្យា ។

52

# ២.៦. លក្ខខណ្ឌនៃកិច្ចសន្យា

ក). កិច្ចសន្យាការងារសាងសង់

ខ). កិច្ចសន្យាការងារសេវាកម្មដែលមានលក្ខណៈជាកញ្ចប់

គ). កិច្ចសន្យាសម្រាប់ការងារថែទាំ

| កាលវិភាគទូទាត់ប្រាក់ | | | |
|---|---|---|---|
| ជំហាននៃការបើកប្រាក់ | ចំនួនថវិកា (ជារៀល) | កាលបរិច្ឆេទ | លក្ខខណ្ឌនៃការទូទាត់ប្រាក់ (ចំនួន% នៃការងារកិច្ចសន្យាដែលត្រូវតែបញ្ចប់) |
| | | | |
| | | | |
| | | | |
| ចំនួនសរុប | | | |



# ២.៧. ការបរិយាយលម្អិតអំពីការងារថែទាំ

- **ការងារដែលត្រូវធ្វើ** : រៀបរាប់ អំពីការងារដែលតម្រូវឱ្យអ្នកទទួលការបំពេញ និងត្រូវភ្ជាប់ជាមួយនូវផែនទីគម្រោង។
- **ទំហំការងារ** : រៀបរាប់លំអិតអំពីទំហំការងារដើម្បីឱ្យអ្នកទទួលការអាចប៉ាន់ស្មានតម្លៃនៃការងារនោះបាន។
- **ការពិពណ៌នាអំពីស្ថានភាពល្អដែលត្រូវបំពេញ** : ត្រូវកំណត់អំពីសូចនាករទាំងឡាយនៃស្ថានភាពល្អនេះ ដែលត្រូវត្រួតពិនិត្យដោយគណៈកម្មការគ្រប់គ្រងគម្រោង។
- **ការពិពណ៌នាអំពីស្ថានភាពបច្ចុប្បន្ន** : ត្រូវពិពណ៌នាលំអិតអំពីស្ថានភាពជាក់ស្តែងក្នុងពេលបច្ចុប្បន្ននេះ ដោយប្រៀបធៀបទៅនឹងស្ថានភាពដែលបានរៀបរាប់នៅចំណុចទី៣។

# ២.៨. ព័ត៌មានកិច្ចសន្យា

លេខកិច្ចសន្យាមានទម្រង់ជា :XXXXXX / YY / NN / SS

- **XXXXXX** គឺជាលេខកូដប្រព័ន្ធព័ត៌មានភូមិសាស្ត្រពេញលេញរបស់ឃុំ សង្កាត់
- **YY** គឺជាលេខតំណាងឆ្នាំ (ឧទាហរណ៍ : ០៨ មានន័យថាឆ្នាំ២០០៨)
- **NN** គឺជាលេខកិច្ចសន្យា (ឧទាហរណ៍ : ០១ មានន័យថា កិច្ចសន្យាលេខ១)
- **SS** គឺជាលេខតំណាងឱ្យចំនួនលើកនៃការចុះកិច្ចសន្យានីមួយៗ។ ឧ. : ០១ មានន័យថា ចុះកិច្ចសន្យាលើក១ជាមួយអ្នកទទួលការម្នាក់ ។ បើអ្នកទទួលការនេះបោះបង់ចោលកិច្ចសន្យា ឃុំ សង្កាត់ចុះកិច្ចសន្យាជាមួយអ្នកទទួលការថ្មី គឺ ០២ ។
- ឧ. កិច្ចសន្យាទី១ ចុះកិច្ចសន្យាលើកទី១ : ៩៨៧៦៥៤/០៨/០១/០១
  បើចុះកិច្ចសន្យាលើកទី២ : ៩៨៧៦៥៤/០៨/០១/០២



# ២.៩. ការកែសម្រួលកិច្ចសន្យា

- មេឃុំ ចៅសង្កាត់ និងអ្នកទទួលការ ឬអ្នកផ្តល់សេវាកម្មមានសិទ្ធិព្រមព្រៀងគ្នាដើម្បីកែសម្រួលកិច្ចសន្យា។
- កិច្ចសន្យាអាចធ្វើការកែសម្រួលទៅលើចំណុចមួយចំនួនខាងក្រោម :
  – ចំនួនលទ្ធផលនៃកិច្ចសន្យា
  – ទីតាំងលទ្ធផល
  – ពេលវេលាអនុវត្តកិច្ចសន្យា
  – កាលវិភាគទូទាត់
  – អ្នកត្រួតពិនិត្យបច្ចេកទេស
- ការកែសម្រួលកិច្ចសន្យាត្រូវតែបំពេញនៅក្នុងទម្រង់កែសម្រួលកិច្ចសន្យា ហើយត្រូវភ្ជាប់ទម្រង់នេះទៅនឹងឯកសារកិច្ចសន្យា។

## ២.៩. ការកែសម្រួលកិច្ចសន្យា (ត)

- បើការកែសម្រួលនោះពាក់ព័ន្ធនឹងព័ត៌មានកិច្ចសន្យា និងផែនកាការងារ មេឃុំ ចៅសង្កាត់ អ្នកត្រួតពិនិត្យបច្ចេកទេស និងអ្នកទទួលការ ត្រូវធ្វើការកែសម្រួល :
  - ព័ត៌មានកិច្ចសន្យាឱ្យស្របតាមការកែសម្រួលកិច្ចសន្យា ហើយសរសេរបន្ថែម ព័ត៌មានកិច្ចសន្យាកែសម្រួលលើកទី........។ ព័ត៌មានកិច្ចសន្យានេះ រៀបចំ៣ច្បាប់ : រក្សាទុកសំណុំកែសារគម្រោង រតនាគារខេត្ត និងអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុង ។
  - ផែនការការងារឱ្យស្របតាមការកែសម្រួលកិច្ចសន្យា ហើយសរសេរបន្ថែម ផែនការការងារកែសម្រួលលើកទី.....។ ផែនការនេះរៀបចំ២ច្បាប់ : រក្សាទុកសំណុំឯកសារគម្រោង និងអ្នកទទួលការ ឬអ្នកផ្តល់សេវាកម្ម។



## ២.៩. ការកែសម្រួលកិច្ចសន្យា (ត)

- កិច្ចសន្យាមិនអាចធ្វើការកែសម្រួលបានទេនូវចំណុចខាងក្រោម :
  - ប្រភេទនៃលទ្ធផលកិច្ចសន្យា
  - គុណភាពបច្ចេកទេសរបស់កិច្ចសន្យា
  - តម្លៃឯកតានៃលទ្ធផលកិច្ចសន្យា
- បើក្រុមប្រឹក្សាឃុំ សង្កាត់មានបំណងចង់ផ្លាស់ប្តូរចំណុចដូចបានរៀបរាប់ខាងលើនេះបន្ទាប់ពីដេញថ្លៃ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវតែលុបចោលកិច្ចសន្យា ហើយរៀបចំផ្លាស់ប្តូរគម្រោង និងដំណើរការលទ្ធកម្មជាថ្មីឡើងវិញ។

# សៀវភៅណែនាំស្តីពី
# ការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់

## ៣. ការត្រួតពិនិត្យកិច្ចសន្យា និងការទូទាត់

59

## ៣. ការត្រួតពិនិត្យកិច្ចសន្យា និងការទូទាត់

៣.១. ការប្រជុំចាប់ផ្តើមអនុវត្តការងារ

៣.២. ការតាមដានការអនុវត្តកិច្ចសន្យា

៣.៣. គំនូសប្លង់ (សម្រាប់ការងារសាងសង់)

៣.៤. សៀវភៅកំណត់ហេតុការងារនៅការដ្ឋាន (សម្រាប់ការងារសាងសង់)

៣.៥. ការពិនិត្យបញ្ជាក់លើលទ្ធផលការងារ និងការអនុម័តការទូទាត់

៣.៦. ការពន្យារពេល

៣.៧. ការប្រជុំបញ្ចប់ការងារ

៣.៨. ការតាមដាននៅក្នុងអំឡុងពេលថែទាំ (កិច្ចសន្យាការងារសាងសង់)

៣.៩. របាយការណ៍បញ្ចប់កិច្ចសន្យា

៣.១០. ការអនុវត្តបញ្ជាទិញ

60

# ៣.១. ការប្រជុំចាប់ផ្តើមអនុវត្តការងារ

- មេឃុំ ចៅសង្កាត់ត្រូវរៀបចំការប្រជុំគណៈកម្មការគ្រប់គ្រងគម្រោងមួយ នៅការដ្ឋានមុនពេលចាប់ផ្តើមអនុវត្តការងារកិច្ចសន្យា ។ អ្នកទទួលការ មេការ ឬអ្នកផ្តល់សេវាកម្ម និងអ្នកត្រួតពិនិត្យបច្ចេកទេស ត្រូវតែចូលរួមក្នុងការប្រជុំនេះ ។
- អ្នកសម្របសម្រួលស្រុក ខណ្ឌ ក៏ត្រូវចូលរួមក្នុងកិច្ចប្រជុំនេះផងដែរ ។
- គោលបំណងនៃការប្រជុំនេះ គឺដើម្បី :
  - គណៈកម្មការគ្រប់គ្រងគម្រោង មេការ ឬអ្នកផ្តល់សេវាកម្ម និងអ្នកត្រួតពិនិត្យបច្ចេកទេសបានស្គាល់គ្នា ។
  - បញ្ជាក់ថាទីតាំងពិតប្រាកដនៃលទ្ធផលគម្រោងដែលត្រូវសាងសង់នោះស្ថិតនៅទីណា ។
  - ដោះស្រាយបញ្ហាបន្តិចបន្តួចបើមាន ។

61

# ៣.២. ការតាមដានការអនុវត្តកិច្ចសន្យា

**តួនាទីរបស់តំណាងម្ចាស់គម្រោង :**

- តំណាងម្ចាស់គម្រោងធ្វើការតាមដានមើលការអនុវត្តកិច្ចសន្យារាល់ថ្ងៃក្នុងនាមមេឃុំ ចៅសង្កាត់ ។
- តំណាងម្ចាស់គម្រោងនឹងប្រើប្រាស់បញ្ជីត្រួតពិនិត្យបច្ចេកទេស ដែលបានទទួលពីអ្នកត្រួតពិនិត្យបច្ចេកទេស ដើម្បីតាមដាន និងត្រួតពិនិត្យការអនុវត្តកិច្ចសន្យាជាប្រចាំរបស់អ្នកទទួលការ ឬអ្នកផ្តល់សេវាកម្ម ។

62

## ៣.២. ការតាមដានការអនុវត្តកិច្ចសន្យា (ត)

### តួនាទីរបស់អ្នកត្រួតពិនិត្យបច្ចេកទេស :

- ផ្ដល់យោបល់ដល់មេឃុំ ចៅសង្កាត់ និងអ្នកទទួលការ ឬអ្នកផ្ដល់សេវាកម្មអំពីបញ្ហាបច្ចេកទេស ។
- ផ្ដល់បញ្ជីត្រួតពិនិត្យបច្ចេកទេសទៅតាមគម្រោងនីមួយៗ និងពន្យល់អំពីរបៀបប្រើប្រាស់បញ្ជីនេះ ។
- បង្រៀនគណៈកម្មការគ្រប់គ្រងគម្រោង ឬតំណាងម្ចាស់គម្រោងអំពីចំណុចសំខាន់ៗផ្នែកបច្ចេកទេស ។
- រៀបចំរបាយការណ៍រីកចម្រើនដែលបញ្ជាក់ទៅលើបរិមាណ និងគុណភាពការងារដែលបានធ្វើដោយអ្នកទទួលការ ឬអ្នកផ្ដល់សេវាកម្ម ទៅតាមដំណាក់កាលបច្ចេកទេសសំខាន់ៗ និងទៅតាមការស្នើសុំរបស់មេឃុំ ចៅសង្កាត់ ។



## ៣.៣. គំនូសប្លង់ (សម្រាប់ការងារសាងសង់)

- តំណាងម្ចាស់គម្រោង មេការ និងអ្នកត្រួតពិនិត្យបច្ចេកទេសម្នាក់ៗ ត្រូវមានគំនូសប្លង់ក្នុងម្នាក់១ច្បាប់ ។
- គំនូសប្លង់ទាំងនេះ គឺសម្រាប់ប្រើប្រាស់ក្នុងការអនុវត្តការងារ និងតាមដានការរីកចម្រើននៃការសាងសង់ ។
- អ្នកទទួលការទទួលខុសត្រូវក្នុងការថតចម្លងគំនូសប្លង់ និងចែកគំនូសប្លង់នេះទៅតំណាងម្ចាស់គម្រោងដែលត្រូវការប្រើប្រាស់វា នៅក្នុងពេលប្រជុំចាប់ផ្ដើមអនុវត្តការងារ ។

# ៣.៤.សៀវភៅកំណត់ហេតុការងារនៅការដ្ឋាន

- មេការត្រូវមានសៀវភៅកំណត់ហេតុ១ក្បាល ដែលទុកជាប់ខ្លួនជានិច្ចនៅការដ្ឋាន ។
- តំណាងរបស់ម្ចាស់គម្រោងមានសិទ្ធិក្នុងការអាន និងសរសេរសេចក្តីសង្កេតរបស់ខ្លួននៅលើសៀវភៅកំណត់ហេតុនេះ ។
- អ្នកត្រួតពិនិត្យបច្ចេកទេសអាចអាន និងសរសេរសេចក្តីណែនាំ ឬការផ្តល់យោបល់ផ្សេងៗសម្រាប់មេការ ។
- អ្នកត្រួតពិនិត្យបច្ចេកទេសត្រូវសរសេរមតិយោបល់ ឬការណែនាំនានា ចុះកាលបរិច្ឆេទ និងចុះហត្ថលេខានៃរាល់ការចុះត្រួតពិនិត្យបច្ចេកទេសរបស់ខ្លួនទាំងអស់ ។
- នៅពេលបញ្ចប់ការសាងសង់ មេការត្រូវប្រគល់សៀវភៅកំណត់ហេតុការងារនេះដល់មេឃុំ ចៅសង្កាត់ នៅក្នុងពេលប្រជុំបិទការដ្ឋាន ហើយមេឃុំ ចៅសង្កាត់ត្រូវរក្សាទុកសៀវភៅនេះនៅក្នុងសំណុំឯកសារគម្រោង ។



# ៣.៥. ការពិនិត្យបញ្ជាក់លើលទ្ធផលការងារ និងការអនុម័តការទូទាត់

- អ្នកទទួលការ ឬអ្នកផ្តល់សេវាកម្មមិនត្រូវបានទទួលការទូទាត់ណាមួយ ក្នុងលក្ខណៈជាបុរេប្រទាននោះទេ លើកលែងតែអង្គភាពមិនរកប្រាក់ចំណេញ ។
- ការទូទាត់អាច ធ្វើទៅបានតែចំពោះការងារដែលបានបញ្ចប់តាមល័ក្ខខ័ណ្ឌកិច្ចសន្យា និងគុណភាពអាចទទួលយកបានប៉ុណ្ណោះ ។
- អ្នកត្រួតពិនិត្យបច្ចេកទេសពិនិត្យបញ្ជាក់នូវបរិមាណ និងគុណភាពការងារដែលបានបំពេញដោយអ្នកទទួលការ ឬអ្នកផ្តល់សេវាកម្ម ។

## ៣.៥. ការពិនិត្យបញ្ជាក់លើលទ្ធផលការងារ និងការអនុម័តការទូទាត់ (ត)

- អ្នកត្រួតពិនិត្យបច្ចេកទេសរៀបចំរបាយការណ៍រីកចម្រើននៃការអនុវត្តកិច្ចសន្យាទៅតាមដំណាក់កាលបច្ចេកទេសសំខាន់ៗ ដែលបានកំណត់នៅក្នុងផែនការការងារ និងរបាយការណ៍បញ្ចប់កិច្ចសន្យាឱ្យទៅមេឃុំចៅសង្កាត់ ។
- មេឃុំ ចៅសង្កាត់ត្រូវរៀបចំប្រជុំគណៈកម្មការគ្រប់គ្រងគម្រោងនៅការដ្ឋានមុននឹងអនុម័ត ការទូទាត់ឱ្យទៅអ្នកទទួលការ ឬអ្នកផ្តល់សេវាកម្ម ។
- កំណត់ហេតុនៃការប្រជុំនេះច្បាប់ដើម ត្រូវភ្ជាប់ជាមួយអាណត្តិបើកប្រាក់ផ្ញើទៅរតនាគារខេត្ត ក្រុង ។



## ៣.៥. ការពិនិត្យបញ្ជាក់លើលទ្ធផលការងារ និងការអនុម័តការទូទាត់ (ត)

- ក្នុងករណីមេឃុំ ចៅសង្កាត់ត្រូវបង់ប្រាក់ក្នុងអត្រា២%ក្នុង១ខែនៃចំនួនទឹកប្រាក់ដែលត្រូវទូទាត់ឱ្យអ្នកទទួលការ ឬអ្នកផ្តល់សេវា មេឃុំចៅសង្កាត់អាចប្រើប្រាស់ :
  - ថវិកាដែលសល់ពីការដេញថ្លៃ
  - ថវិកាដែលសល់ពីការចំណាយនៃខ្ទង់ថវិកានានា ដោយធ្វើកែតម្រូវគម្រោងថវិកាឃុំ ។
- មេឃុំ ចៅសង្កាត់ត្រូវអនុវត្តនីតិវិធីទូទាត់ដូចខាងក្រោម :
  - កោះប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីពិនិត្យអំពីករណីដែលនាំឱ្យមានការយឺតយ៉ាវ និងសម្រេចអំពីថវិកាដែលត្រូវបង់ឱ្យអ្នកទទួលការ ឬអ្នកផ្តល់សេវាកម្ម
  - ចេញអាណត្តិបើកប្រាក់ទៅតាមចំនួនទឹកប្រាក់ដែលត្រូវបង់ឱ្យទៅអ្នកទទួលការ ឬអ្នកផ្តល់សេវាកម្មដើម្បីទូទាត់ ដោយភ្ជាប់ជាមួយនូវកំណត់ហេតុនៃការប្រជុំក្រុមប្រឹក្សាឃុំ

ទម្រង់ទី៥៥

| របាយការណ៍រីកចម្រើននៃកិច្ចសន្យាការងារសាងសង់ | | |
|---|---|---|
| ខេត្ត ក្រុង : | ស្រុក ខណ្ឌ : | ឃុំ សង្កាត់ : |
| ឈ្មោះគម្រោង | | |
| លេខកិច្ចសន្យា | | |
| ឈ្មោះអ្នកទទួលការ | | |
| ឈ្មោះអ្នកត្រួតពិនិត្យបច្ចេកទេស | | |
| កាលបរិច្ឆេទចុះត្រួតពិនិត្យ | | |
| ១. ការពិពណ៌នាអំពីការរីកចម្រើននៃការងារ : | | |
| ២. អត្រាភាគរយនៃការបញ្ចប់ | | |
| ៣. តើសម្ភារៈទាំងនោះមានគុណភាពដូចបានសរសេរក្នុងកិច្ចសន្យាដែរឬទេ? (បើមិនមានគុណភាពដូចចែងក្នុងកិច្ចសន្យា ចូរពន្យល់នូវចំណុចខ្វះខាតទាំងនោះ) | | |
| ៤. តើទឹកដៃការងារមានគុណភាព ដូចបានសរសេរក្នុងកិច្ចសន្យាដែរឬទេ? (បើមិនមានគុណភាពដូចចែងក្នុងកិច្ចសន្យា ចូរពន្យល់នូវចំណុចខ្វះខាតទាំងនោះ) | | |
| ៥. តើសំណង់នោះដូចគ្នានឹងគំនូសប្លង់ដែរឬទេ? (បើមិនមានគុណភាពដូចចែងក្នុងកិច្ចសន្យា ចូរពន្យល់នូវចំណុចដែលខុសទាំងនោះ) | | |
| ៦. យោបល់ផ្សេងៗ : | | |

ថ្ងៃទី...... ខែ.......... ឆ្នាំ.......

**អ្នកត្រួតពិនិត្យបច្ចេកទេស**



ទម្រង់៥៧

| របាយការណ៍រីកចម្រើននៃកិច្ចសន្យាសេវាកម្ម | | |
|---|---|---|
| ខេត្ត ក្រុង : | ស្រុក ខណ្ឌ : | ឃុំ សង្កាត់ : |
| ឈ្មោះគម្រោង | | |
| លេខកិច្ចសន្យា | | |
| ឈ្មោះផ្តល់សេវាកម្ម | | |
| ឈ្មោះអ្នកត្រួតពិនិត្យបច្ចេកទេស | | |
| កាលបរិច្ឆេទចុះត្រួតពិនិត្យ | | |
| ១. ការពិពណ៌នាអំពីការរីកចម្រើននៃការងារ : | | |
| ២. អត្រាភាគរយនៃការបញ្ចប់ | | |
| ៣. តើសម្ភារៈ/ពូជទាំងនោះមានគុណភាពដូចបានសរសេរក្នុងកិច្ចសន្យាដែរឬទេ? | | |
| ៤. តើការអនុវត្តការងារមានគុណភាព ដូចបានសរសេរក្នុងកិច្ចសន្យាដែរឬទេ? | | |
| ៥. យោបល់ផ្សេងៗ : | | |

ថ្ងៃទី...... ខែ.......... ឆ្នាំ.......

**អ្នកត្រួតពិនិត្យបច្ចេកទេស**

## ៣.៦. ការពន្យារពេល

- បើការងារត្រូវបានពន្យារពេល ម្ចាស់គម្រោងមានសិទ្ធិកាត់ប្រាក់ពីអ្នកទទួលការ ឬអ្នកផ្តល់សេវាកម្មចំនួន០.១% **នៃតម្លៃកិច្ចសន្យា រៀងរាល់ថ្ងៃ** បន្ទាប់ពីកាលបរិច្ឆេទបញ្ចប់ការងារ រហូតដល់ថ្ងៃដែលអ្នកទទួលការ ឬអ្នកផ្តល់សេវាកម្មបានអនុវត្តការងារចប់ទាំងស្រុង ។
- ការកាត់ប្រាក់នេះយ៉ាងច្រើនបំផុតត្រឹម១០% **នៃតម្លៃកិច្ចសន្យា**។
- មុននឹងឈានដល់ការសម្រេចក្នុងការកាត់ប្រាក់ចំនួន០.១% នៃតម្លៃកិច្ចសន្យាក្នុងមួយថ្ងៃ មេឃុំ ចៅសង្កាត់ ត្រូវចេញលិខិតមួយជម្រាបដល់អ្នកទទួលការ ឬអ្នកផ្តល់សេវាកម្មដើម្បីចាប់ផ្តើម ឬបន្តអនុវត្តកិច្ចសន្យា។



## ៣.៦. ការពន្យារពេល (ត)

- ប្រាក់ដែលឃុំ សង្កាត់កាត់ពីអ្នកទទួលការ ឬអ្នកផ្តល់សេវាកម្ម ត្រូវរក្សាទុកនៅខ្ទង់ថវិកានៃកិច្ចសន្យាដដែល ហើយថវិកានេះអាចត្រូវបានប្រើប្រាស់ :
  - ពង្រីកចំនួនលទ្ធផលកិច្ចសន្យា
  - អនុវត្តគម្រោងផ្សេង។ ក្នុងករណីនេះត្រូវធ្វើការកែតម្រូវថវិកា និងរៀបចំ គម្រោងនោះទៅតាមនីតិវិធី ។
  - រក្សាទុកសម្រាប់ប្រើប្រាស់នៅឆ្នាំបន្ទាប់ ។

## ៣.៧. ការប្រជុំបញ្ចប់ការងារ

ក). កិច្ចសន្យាការងារសាងសង់ (ការប្រជុំបិទការដ្ឋាន)

- នៅពេលការងារត្រូវបានបញ្ចប់១០០% មេឃុំ ចៅសង្កាត់ត្រូវរៀបចំកិច្ចប្រជុំគណៈកម្មការគ្រប់គ្រងគម្រោងម្តងទៀត ។
- កិច្ចប្រជុំនេះនឹងត្រូវរៀបចំតាមនីតិវិធីដូចកិច្ចប្រជុំអនុម័តការទូទាត់ដែរ ។
- បើក្នុងកិច្ចប្រជុំនេះ មានការឯកភាពយល់ព្រមឱ្យធ្វើការទូទាត់ នោះថ្ងៃប្រជុំនេះត្រូវចាត់ទុកថាជាថ្ងៃបញ្ចប់ការងារសាងសង់ ។
- ការងារថែទាំ៦ខែ នឹងត្រូវគិតចាប់ផ្តើមពីថ្ងៃនោះទៅ ។



## ៣.៧. ការប្រជុំបញ្ចប់ការងារ (ត)

ខ). កិច្ចសន្យាសេវាកម្ម

- នៅពេលការអនុវត្តកិច្ចសន្យាត្រូវបានបញ្ចប់១០០% មេឃុំ ចៅសង្កាត់ត្រូវរៀបចំកិច្ចប្រជុំគណៈកម្មការគ្រប់គ្រងគម្រោងម្តងទៀត ។
- កិច្ចប្រជុំនេះនឹងត្រូវរៀបចំតាមនីតិវិធីដូចកិច្ចប្រជុំអនុម័តការទូទាត់ដែរ ។
- បើក្នុងកិច្ចប្រជុំនេះ មានការឯកភាពយល់ព្រមឱ្យធ្វើការទូទាត់ នោះថ្ងៃប្រជុំនេះត្រូវចាត់ទុកថាជាថ្ងៃបញ្ចប់កិច្ចសន្យា ។

## ៣.៨. ការតាមដាននៅក្នុងអំឡុងពេលថែទាំ

- ការសាងសង់បញ្ចប់ កិច្ចសន្យាមិនទាន់បញ្ចប់ទេ ព្រោះអ្នកទទួលការនឹងថែទាំក្នុងរយៈពេល៦ខែទៀត ។
- គ្រប់សំណង់របស់ឃុំ សង្កាត់គួរតែមានការថែទាំរយៈពេល៦ខែដំបូង ។
- ថវិកាចុងក្រោយ២០% គឺមិនមែនជាថវិកាសម្រាប់តែការធានាទេ ជាថវិកាសម្រាប់រ៉ាប់រងចំណាយលើការថែទាំក្នុងរយៈពេល៦ខែនេះ ។
- អ្នកទទួលការត្រូវទទួលខុសត្រូវក្នុងការជួសជុលការខូចខាតដែលបណ្តាលមកពីកំហុសរបស់ខ្លួន ឬដោយសារការប្រើប្រាស់ធម្មតា ។
- អ្នកទទួលការមិនទទួលខុសត្រូវក្នុងការជួសជុលការខូចខាតណាមួយដែលបណ្តាលមកពីកំហុសនៅក្នុងគ្រោងការគម្រោង ឬបណ្តាលមកពីព្រឹត្តិការណ៍មិនធម្មតាដែលកើតឡើងនៅក្នុងរយៈពេលថែទាំឡើយ ។



## ៣.៩. របាយការបញ្ចប់កិច្ចសន្យា

ក). កិច្ចសន្យាការងារសាងសង់

- នៅពេលផុតកំណត់នៃរយៈពេលថែទាំ មេឃុំចៅសង្កាត់ និងអ្នកត្រួតពិនិត្យបច្ចេកទេសត្រូវធ្វើការត្រួតពិនិត្យមើលការងារជាថ្មីម្តងទៀត ហើយអ្នកត្រួតពិនិត្យបច្ចេកទេសត្រូវធ្វើរបាយការណ៍បញ្ចប់កិច្ចសន្យា ។
- របាយការណ៍នេះត្រូវយកទៅពិភាក្សានៅក្នុងកិច្ចប្រជុំគណៈកម្មការគ្រប់គ្រងគម្រោងដែលរៀបចំឡើងជាសាធារណៈ នៅការដ្ឋានគម្រោង ។

# ៣.៩. របាយការបញ្ចប់កិច្ចសន្យា

## ១). កិច្ចសន្យាសេវាកម្ម

- នៅពេលសកម្មភាពទាំងអស់ដែលបានកំណត់នៅក្នុងកិច្ចសន្យា និងផែនការការងារត្រូវបានអនុវត្តចប់សព្វគ្រប់ មេឃុំចៅសង្កាត់ និងអ្នកត្រួតពិនិត្យបច្ចេកទេសត្រូវធ្វើការត្រួតពិនិត្យមើលការផ្តល់សេវាកម្ម និងសម្ភារៈទាំងនោះជាថ្មីម្តងទៀត ហើយអ្នកត្រួតពិនិត្យបច្ចេកទេសត្រូវធ្វើរបាយការណ៍បញ្ចប់កិច្ចសន្យា។
- របាយការណ៍នេះត្រូវយក ទៅពិភាក្សានៅក្នុងកិច្ចប្រជុំគណៈកម្មការគ្រប់គ្រងគម្រោងដែលរៀបចំឡើងជាសាធារណៈ នៅទីតាំងគម្រោង។

77

ទម្រង់ទី៥៦

| របាយការណ៍បញ្ចប់កិច្ចសន្យាការងារសាងសង់<br>(នៅពេលបញ្ចប់រយៈពេលថែទាំ) | | |
|---|---|---|
| ខេត្ត ក្រុង : | ស្រុក ខណ្ឌ : | ឃុំ សង្កាត់ : |
| ឈ្មោះគម្រោង | | |
| លេខកិច្ចសន្យា | | |
| ឈ្មោះអ្នកទទួលការ | | |
| ឈ្មោះអ្នកត្រួតពិនិត្យបច្ចេកទេស | | |
| កាលបរិច្ឆេទចុះត្រួតពិនិត្យ | | |
| ១. ពិពណ៌នាអំពីស្ថានភាពនៃលទ្ធផល : | | |
| ២. ការងារដែលអ្នកទទួលការត្រូវបំពេញ មុននឹងទូទាត់ចុងក្រោយ | | |
| ៣. យោបល់ផ្សេងៗ : | | |

ថ្ងៃទី...... ខែ........... ឆ្នាំ.......

**អ្នកត្រួតពិនិត្យបច្ចេកទេស**

78

ទម្រង់៥៨

| របាយការណ៍បញ្ចប់កិច្ចសន្យាសេវាកម្ម | | |
|---|---|---|
| ខេត្ត ក្រុង : | ស្រុក ខណ្ឌ : | ឃុំ សង្កាត់ : |
| ឈ្មោះគម្រោង | | |
| លេខកិច្ចសន្យា | | |
| ឈ្មោះផ្តល់សេវាកម្ម | | |
| ឈ្មោះអ្នកត្រួតពិនិត្យបច្ចេកទេស | | |
| កាលបរិច្ឆេទចុះត្រួតពិនិត្យ | | |
| ១. ការពិពណ៌នាអំពីការរីកចម្រើននៃការងារ : | | |
| ២. អត្រាភាគរយនៃការបញ្ចប់ | | |
| ៣. តើសម្ភារៈ/ពូជទាំងនោះមានគុណភាពដូចបានសរសេរក្នុងកិច្ចសន្យាដែរឬទេ? | | |
| ៤. តើការអនុវត្តការងារមានគុណភាព ដូចបានសរសេរក្នុងកិច្ចសន្យាដែរឬទេ? | | |
| ៥. យោបល់ផ្សេងៗ : | | |

ថ្ងៃទី...... ខែ.......... ឆ្នាំ.......

**អ្នកត្រួតពិនិត្យបច្ចេកទេស**



# ៣.១០. ការអនុវត្តការបញ្ជាទិញ

- ចំពោះការបញ្ជាទិញ មេឃុំ ចៅសង្កាត់ត្រូវចេញលិខិតបញ្ជាទិញទៅអ្នកផ្គត់ផ្គង់ទំនិញ ទៅតាមអនុសាសន៍ របស់គណៈកម្មការលទ្ធកម្ម ។
- អ្នកផ្គត់ផ្គង់ទំនិញត្រូវដឹកជញ្ជូនសម្ភារៈ ឬទំនិញឱ្យដល់ទីកន្លែងតាមកាលបរិច្ឆេទ ដូចដែលបានកំណត់ក្នុងលិខិតបញ្ជាទិញ។
- បើអ្នកផ្គត់ផ្គង់ទំនិញមិនបានដឹកជញ្ជូនសម្ភារៈឱ្យបានតាមការកំណត់ ឬក្នុងរយៈពេល**៥ថ្ងៃធ្វើការ** សម្រាប់ការទិញដែលមានទំហំទឹកប្រាក់**តិចជាង២លានរៀល** ឬរយៈពេល**១០ថ្ងៃធ្វើការ** សម្រាប់ការទិញណាដែលមានទំហំទឹកប្រាក់**លើសពី២លានរៀល** មេឃុំចៅសង្កាត់មានសិទ្ធិលុបចោលការបញ្ជាទិញនេះ ហើយអាចធ្វើការបញ្ជាទិញពីអ្នកផ្គត់ផ្គង់ទំនិញផ្សេងទៀត ។

## ៣.១០. ការអនុវត្តការបញ្ជាទិញ

- នៅពេលទំនិញត្រូវបានផ្គត់ផ្គង់ចប់សព្វគ្រប់ មេឃុំ ចៅសង្កាត់ និងអ្នកត្រួតពិនិត្យបច្ចេកទេសត្រូវធ្វើការត្រួតពិនិត្យទំនិញទាំងនោះ :
  - អ្នកផ្គត់ផ្គង់បានផ្តល់ទំនិញតាមប្រភេទត្រឹមត្រូវដូចដែលបានបញ្ជាទិញ
  - អ្នកផ្គត់ផ្គង់បានផ្តល់ទំនិញតាមបរិមាណត្រឹមត្រូវ
  - ទំនិញស្ថិតក្នុងល័ក្ខខ័ណ្ឌល្អ មិនមានការខូចខាតដោយប្រការណាមួយ
  - ឧបករណ៍ទាំងនោះត្រូវមានដំណើរការត្រឹមត្រូវ និង
  - ល័ក្ខខ័ណ្ឌផ្សេងៗទៀត ដែលត្រូវបំពេញក្នុងការទិញ
- អ្នកត្រួតពិនិត្យបច្ចេកទេសធ្វើរបាយការណ៍ទទួលទំនិញឱ្យមេឃុំចៅសង្កាត់ ។ បើរបាយការណ៍បង្ហាញថា អ្វីៗត្រឹមត្រូវទាំងអស់ហើយនោះ មេឃុំ ចៅសង្កាត់ ត្រូវចេញអាណត្តិបើកប្រាក់ ។



# សៀវភៅណែនាំស្តីពី ការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់

## ៤. ការតាមដាន និងការវាយតម្លៃ គម្រោងមូលនិធិឃុំ សង្កាត់

## ៤.១. គោលបំណងនៃការតាមដាន និងវាយតម្លៃ

- **ការតាមដាន** គឺជាដំណើរការប្រមូលព័ត៌មានអំពីការរីកចម្រើនរបស់កិច្ចសន្យា។ ការប្រមូលព័ត៌មាននេះ ត្រូវធ្វើឡើងនៅគ្រប់ពេលនៃការអនុវត្តកិច្ចសន្យា។

- គោលបំណងនៃការតាមដាន គឺដើម្បីជួយក្នុងការវិនិច្ឆ័យ ថាតើសកម្ម ភាពទាំងឡាយ ត្រូវបានអនុវត្តទៅតាមផែនការគ្រោងទុកដែរឬទេ? ។ ព័ត៌មានដែលប្រមូលបាន ត្រូវបានយកមកប្រើប្រាស់ជាមូលដ្ឋាន ក្នុងការធ្វើសេចក្តីសម្រេចអំពីការកែលម្អការគ្រប់គ្រង និងការអនុវត្តគម្រោង។

83




ក្រុមការងារ តាមដានការអនុវត្ត គម្រោងឃុំ/សង្កាត់

- **ការវាយតម្លៃ** គឺជាដំណើរការវាស់វែងលទ្ធផលរបស់កិច្ចសន្យា ។ ការវាយតម្លៃគម្រោង គឺមិនមែនជាសកម្មភាពដែលត្រូវធ្វើជាប្រចាំដូចការតាមដាននោះទេ ប៉ុន្តែវាជាសកម្មភាពដែលត្រូវអនុវត្តដាច់ដោយ ឡែកដែលជាទូទៅនៅពេលបញ្ចប់គម្រោង ។
- ក្នុងការវាយតម្លៃនេះយើងត្រូវ :
  - វាយតម្លៃជាទូទៅលើបទដ្ឋានបច្ចេកទេសដែលសម្រេចបាន
  - វាយតម្លៃលើសមត្ថភាព និងការអនុវត្តរបស់អ្នកទទួលការ
  - វាយតម្លៃលើសមត្ថភាព និងការអនុវត្តរបស់អ្នកបច្ចេកទេស
- **គោលបំណងនៃការវាយតម្លៃ** គឺដកស្រង់បទពិសោធន៍ពីការវាយតម្លៃនេះសម្រាប់យកទៅប្រើប្រាស់ក្នុងការអនុវត្តគម្រោងនាពេលអនាគត ។



## ៤.២. តួនាទី និងការទទួលខុសត្រូវ

១. ក្រុមប្រឹក្សាឃុំ សង្កាត់

២. ជនបង្គោលតាមដានត្រួតពិនិត្យ និងវាយតម្លៃឃុំ សង្កាត់

៣. មេឃុំ ចៅសង្កាត់/តំណាងម្ចាស់គម្រោង

៤. មន្ត្រីគាំទ្របច្ចេកទេស/អ្នកត្រួតពិនិត្យបច្ចេទេស

៥. អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុង

៦. គណៈកម្មការសវនកម្មបច្ចេកទេស

៧. នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន និងក្រសួងមហាផ្ទៃ



ក្រុមការងារ វាយតម្លៃ គម្រោងឃុំ/សង្កាត់

## ៤.៣.ការតាមដានលើការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់

ក្នុងតារាង នឹងបង្ហាញអំពីអ្វីដែលត្រូវធ្វើការតាមដាន អ្នកទទួលខុសត្រូវ របៀបធ្វើការតាមដាន (ឧបករណ៍តាមដាន) របៀបកត់ត្រាទិន្នន័យ និងពេលវេលាដែលត្រូវធ្វើការតាមដាន។

១- តារាងបង្ហាញពី **ការតាមដានគម្រោងមូលនិធិឃុំ សង្កាត់** (៤.៣.១)

២- តារាងបង្ហាញពី **ការវាយតម្លៃគម្រោងមូលនិធិឃុំ សង្កាត់** (៤.៣.២)

# ៤.៤. សវនកម្មបច្ចេកទេស

- **សវនកម្មបច្ចេកទេស** គឺជាការអង្កេតមួយទៅលើកិច្ចសន្យាដែលបានអនុវត្តចប់សព្វគ្រប់ ។
- **គោលបំណង** នៃការធ្វើសវនកម្មបច្ចេកទេសនេះ គឺដើម្បីវាយតម្លៃដំណើរការអនុវត្តកិច្ចសន្យា និងដើម្បីកំណត់ថាតើនៅមានចំណុចអ្វីខ្លះទៀតដែលអាចធ្វើការ កែលម្អនាពេលអនាគត ។
- សវនកម្មបច្ចេកទេសមិនមែនជាផ្នែកមួយនៃការត្រួតពិនិត្យកិច្ចសន្យាទេ ។ សវនកម្មបច្ចេកទេសធ្វើការអង្កេត និងរាយការណ៍អំពីបញ្ហានានាដែលកើតឡើងជូនអភិបាលខេត្ត ក្រុង ក្នុងអំឡុងពេលអនុវត្តកិច្ចសន្យា ដែលមេឃុំ ចៅសង្កាត់ អ្នកទទួលការ ឬអ្នកផ្គត់ផ្គង់សេវាកម្ម និងអ្នកត្រួតពិនិត្យបច្ចេកទេសមិនអាចដោះស្រាយបាន ។ ៨៩

# តើត្រូវអនុវត្តសវនកម្មបច្ចេកទេសនៅពេលណា?

- សវនកម្មបច្ចេកទេសត្រូវធ្វើឡើងនៅពេលដែលកិច្ចសន្យាបានបញ្ចប់១០០ % ។
- គណៈកម្មការសវនកម្មបច្ចេកទេស ត្រូវធ្វើការជ្រើសរើសគម្រោងមួយចំនួនដើម្បី ធ្វើសវនកម្មប៉ុណ្ណោះ ។
- គណៈកម្មការសវនកម្មបច្ចេកទេសមិនត្រូវធ្វើការជ្រើសរើសក្នុងការធ្វើសវនកម្មចំពោះកិច្ចសន្យាដែលមិនទាន់បានបញ្ចប់ និងមិនទាន់បានធ្វើការទូទាត់ចប់សព្វគ្រប់ ។
- ការធ្វើសវនកម្មបច្ចេកទេសលើគម្រោងមូលនិធិឃុំ សង្កាត់ ចំណាយពេលវេលាប្រហែលមួយព្រឹក ឬមួយល្ងាចតែប៉ុណ្ណោះ ។

# អ្នកណាខ្លះគួរតែស្ថិតនៅក្នុងគណៈកម្មការ សវនកម្មបច្ចេកទេស?

សមាសភាពរបស់គណៈកម្មការនេះ គួរមានដូចខាងក្រោម :

- សមាជិករបស់គណៈកម្មាធិការប្រតិបត្តិខេត្ត ក្រុង ១រូប
- ផ្នែកគាំទ្របច្ចេកទេស ១រូប (សម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធ)
- អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុង ១រូប
- សមាជិក ឬទីប្រឹក្សាផ្សេងៗទៀត បើសិនជាចាំបាច់





សមាសភាពរបស់គណៈកម្មការសវនកម្មបច្ចេកទេសគម្រោងឃុំ/សង្កាត់

# ដំណើរការសម្រាប់ធ្វើសវនកម្មបច្ចេកទេស

- **ជំហានទី១** : ការសិក្សាឯកសារពាក់ព័ន្ធ (របាយការណ៍រីកចម្រើន របាយការណ៍បញ្ចប់កិច្ចសន្យា និងកំណត់ហេតុប្រជុំគណៈកម្មការគ្រប់គ្រងគម្រោង)
- **ជំហានទី២** : ការចុះពិនិត្យទីតាំងលទ្ធផលគម្រោងជាក់ស្តែង (ត្រូវរៀបចំ និងជូន ដំណឹងជាមុន ដើម្បីឱ្យអ្នកពាក់ ព័ន្ធទាំងអស់អាចចូលរួមបាន)

☞ គណៈកម្មការសវនកម្មបច្ចេកទេសត្រូវធ្វើអធិការកិច្ចការងារដែលបានបញ្ចប់ និង ពិភាក្សាជាមួយអ្នកដែលពាក់ព័ន្ធនានា ។ បញ្ហាដែលត្រូវធ្វើការអង្កេតរួមមាន : បរិមាណ និងគុណភាព, ពេលវេលា, បញ្ហា, ផលប៉ះពាល់បរិស្ថាន, គុណភាពការងារ របស់អ្នកទទួលការ... ។ល ។

93



គណៈកម្មការសវនកម្មបច្ចេកទេសជួបពិភាក្សាជាមួយអ្នកដែលពាក់ព័ន្ធនានា

# របាយការណ៍សវនកម្មបច្ចេកទេស

គណៈកម្មការសវនកម្មបច្ចេកទេសត្រូវធ្វើរបាយការណ៍ដោយ ផ្អែកលើទម្រង់ឯកភាពមួយ។ របាយការណ៍នេះ ត្រូវផ្ញើជូនទៅ :

- គណៈកម្មាធិការប្រតិបត្តិខេត្ត ក្រុង
- អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុង
- ផ្នែកគាំទ្របច្ចេកទេស
- អ្នកទទួលការ ឬអ្នកផ្តល់សេវាកម្ម
- ក្រុមប្រឹក្សាឃុំ សង្កាត់






# សូមអរគុណ

# ១. ការរៀបចំគម្រោងមូលនិធិឃុំ សង្កាត់

១.១. ការពិនិត្យអំពីតម្រូវការនៃការសិក្សាផលប៉ះពាល់បរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចរបស់គម្រោង

១.២. ការបង្កើតគណៈកម្មការគ្រប់គ្រងគម្រោង

១.៣. ការរៀបចំក្រុមប្រើប្រាស់

១.៤. ការរៀបចំផែនការសិក្សាគម្រោង

១.៥. ការរៀបចំផែនទីគម្រោង

១.៦. ការសិក្សា និងប្រមូលព័ត៌មានទូទៅ និងព័ត៌មានបច្ចេកទេស

១.៧. ការសិក្សាផលប៉ះពាល់បរិស្ថាន

១.៨. ការសិក្សាដីធ្លី

១.៩. ការរៀបចំរបាយការណ៍ស្ដីពីវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច



# ២.២. ការរៀបចំគម្រោងមូលនិធិឃុំ សង្កាត់

១.១០. ការរៀបចំគ្រោងការគម្រោង

១.១១. ការប៉ាន់ស្មានតម្លៃគម្រោង និងព័ត៌មានលម្អិតនៃលទ្ធផលគម្រោង

១.១២. ផែនការប្រើប្រាស់ និងថែទាំ

១.១៣. ការពិនិត្យ និងអនុម័តគ្រោងការគម្រោង

១.១៤. ការពិនិត្យព័ត៌មានគម្រោងដោយអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុង

១.១៥. ការពិនិត្យបញ្ជាក់បច្ចេកទេស